សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបអនីតិសង្វាស កម្ពុជា-ជប៉ុន

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **សាំង អូន**
លោក **ម៉ិច មេសា**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ប្រៀបធៀបអនីតិសន្ធាស កម្ពុជា-ជប៉ុន

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ  កញ្ញា **សាំង អូន**
លោក **ម៉ិច មេសា**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូយ ធីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**  ឆ្នាំចូលសិក្សា ២០១៥
ជំនាន់ទី២៤ (អាហារូបករណ៍)  ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សាំង អួន** និង **ម៉ិច មេសា** ជាសិស្សថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ក្នុងឆ្នាំសិក្សា២០១៨-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ កូនសូមថ្លែងអំណរគុណចំពោះ៖

**លោកឪពុក សាំង ស្រ៊ី** និង **អ្នកម្តាយ ស ញ៉េន**

**លោកឪពុក ម៉ិច ម៉ុង** និង **អ្នកម្តាយ ប៉ាង សាវរី**

កូនសូមសម្តែងនូវមហាកតញ្ញូតាធមិជាអនេកប្បការ ចំពោះលោកអ្នកមានគុណទាំងពីរ ដែលបានផ្តល់កំណើត និងខិតខំបីបាច់ចិញ្ចឹមរូបកូនតាំងពីក្នុងផ្ទៃ រហូតដល់កូនក្លាយជាយុវជន និង យុវតីពេញរូបរាង ព្រមទាំងទទួលបាននូវការអប់រំទូន្មានរហូតដល់ឧត្តមសិក្សានេះ។ ព្រះគុណដ៏ធំធេងនេះគឺធ្វើឲ្យកូនចងចាំ និងគ្មានអ្វីអាចបំភ្លេចបានឡើយ។ កូនសូមលើកហត្ថប្រណម្យគោរពប្រណិប័តន៍ផ្ញើស្មាដៃនេះ ជូនចំពោះលោកទាំងពីរជាទីគោរពសាការៈដ៏ខ្ពង់ខ្ពស់។

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ជាគ្រឹះស្ថានសិក្សាអប់រំដែលមិនត្រឹមតែផ្តល់នូវសាស្ត្រាចារ្យល្អៗ មានជំនាញក្នុងការផ្ទេរចំណេះដឹងពិតប្រាកដដល់ពួកយើងប៉ុណ្ណោះទេ ថែមជាកន្លែងជួយហាត់ពត់ លត់ដំចរិយាមាយាទ អប់រំស្មារតីឲ្យបណ្តុះខ្លួនក្លាយជាពលរដ្ឋល្អ ជាទំពាំងស្នងឬស្សីដែលប្រទេសជាតិមិនអាចខ្វះបាន។

**មជ្ឈមណ្ឌលអប់រំ និងស្រាវជ្រាវច្បាប់ជប៉ុន** (CJL) ជាកន្លែងបណ្តុះបណ្តាលធនធាននិស្សិតពិតប្រាកដឲ្យយល់ពីជម្រៅនៃការសិក្សារៀនសូត្រ ដែលបានផ្តល់ជាអាហារូបករណ៍ពេញរយៈពេល៤ឆ្នាំជួយឲ្យយើងខ្ញុំមានការវិភាគបានស៊ីជម្រៅបន្ថែមបានមួយកម្រិតទៀតទៅលើសារណា ព្រមទាំងផ្តល់ជាឯកសារនានា ញ៉ាំងឲ្យយើងខ្ញុំមានឱកាសក្នុងការប្រៀបធៀបរវាងប្រព័ន្ធច្បាប់កម្ពុជា និងជប៉ុនដូចមានសេចក្តីរៀបរាប់នៅក្នុងសារណានេះ។

**លោក លោកស្រីសាស្ត្រាចារ្យទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាអ្នកអប់រំប្រៀនប្រដៅទាំងផ្នែកទ្រឹស្តី ទាំងបង្ហឹកផ្នែកការអនុវត្ត លើកទឹកចិត្តស្មារតីឲ្យយើងខ្ញុំមានឆន្ទៈមោះមុតមិនរាថយ រហូតទទួលបាននូវចំណេះដឹងជាសារវន្តក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ ។

ជាពិសេសសូមថ្លែងអំណរគុណចំពោះលោកស្រីសាស្ត្រាចារ្យ **ម៉ួយ ធីតា** ដែលបានចំណាយពេលវេលាទាំងកម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញាស្មារតី ដោយបានបង្ហាត់បង្រៀនយើងខ្ញុំក៏ដូចជាតម្រង់ទិសជួយយើងខ្ញុំឲ្យមានវិធីសាស្ត្រកាន់តែច្បាស់លាស់ ក្នុងការធ្វើការស្រាជ្រាវសារណានេះ លេចចេញជារូបរាងឡើង។

# **អារម្ភកថា**

ជាបឋមនាងខ្ញុំ សាំង អូន និង ខ្ញុំបាទ ប៊ុច មេសា សូមគោរពលោកសាស្ត្រាចារ្យព្រមទាំងស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេស សិស្សនិស្សិតជាទីរាប់អាន។

ក្នុងនាម ជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំនូវសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ក្រោមប្រធានបទស្តីពី **ប្រៀបធៀបអនីតិសង្វាសកម្ពុជា-ជប៉ុន** នេះឡើងដោយសារមើលឃើញថាអនីតិសង្វាសជាបញ្ហាមួយដែលកំពុងកើតឡើងនៅក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះ។ មួយវិញទៀតក្រមរដ្ឋប្បវេណីឆ្នាំ២០០៧របស់កម្ពុជាបាន ទទួលយកការកែប្រែពីក្រមរដ្ឋប្បវេណីជប៉ុនទើបយើងខ្ញុំចង់ដឹងថា តើការដោះស្រាយទៅលើបញ្ហាអនីតិសង្វាសរបស់ជប៉ុន និងកម្ពុជាមានលក្ខណៈដូចគ្នា និងខុសគ្នាដូចម្តេចខ្លះ។ ដើម្បីបន្សល់ទុកជាស្នាដៃដល់ប្អូនៗនិស្សិតជំនាន់ក្រោយងាយស្រួលក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៀត។ ហេតុនេះហើយបានជាយើងខ្ញុំទាំងពីរនាក់ បានសម្រេចចិត្តក្នុងការរៀបចំជាសារណាស្តីពីប្រធានបទមួយនេះ ព្រមទាំងមានការគាំទ្រ និងលើកទឹកចិត្តយ៉ាងពេញទំហឹង របស់លោកស្រីសាស្ត្រាចារ្យ **ម៉ួយ ធីតា** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ចំពោះការសិក្សាស្រាវជ្រាវ ប្រធានបទមួយនេះ គឺធ្វើឡើងតាមរយៈការប្រមូលពត៌មានតាមគេហទំព័រនានា ការសិក្សាទៅលើសាលក្រមនិងសាលដីកាដែលជាសេចក្តីសម្រេចរបស់តុលាការ ការស្វែងយល់អំពីក្រមរដ្ឋប្បវេណីរបស់ជប៉ុនចំពោះការអនុវត្តនៅក្នុងករណីអនីតិសង្វាស និងសារណារបស់សិស្សច្បងដែលបានបញ្ចប់ការសិក្សាជាដើម។

ម្យ៉ាងវិញទៀតយើងខ្ញុំ ក៏សូមអភ័យទោស នូវរាល់កំហុសដែលកើតមានដោយអចេតនា នូវរាល់កង្វះខាតទាំងឡាយដែលមាននៅក្នុងសារណានេះយើងខ្ញុំរងចាំទទួលការរិះគន់ដើម្បីកែលម្អរពីសំណាក់មិត្តអ្នកអានទាំងអស់គ្នា។ ហើយក៏ថ្លែងអំណរគុណ និង គោរពយ៉ាងមានមោទនភាពដល់លោកស្រីសាស្ត្រាចារ្យ **ម៉ួយ ធីតា** ដែលបានខិតខំចំណាយពេលវេលាយ៉ាងមានតម្លៃមកបង្ហាត់បង្រៀន ព្រមទាំងណែនាំឲ្យពួកយើងសិក្សាស្រាវជ្រាវបង្កើតជាសារណានេះឡើង។ មួយវិញទៀតសូមគោរពដល់ជនគ្រប់រូបដែលបានខិតខំចំណាយពេលដ៏មានតម្លៃក្នុងការអាននិងជួយគាំទ្រសៀវភៅនេះ។ ព្រមជាមួយគ្នានេះដែរយើងខ្ញុំ នឹងរងចាំទទួលការរិះគន់ដើម្បីស្តាបនាពីសំណាក់មិត្តអ្នកអានទាំងអស់គ្នា។ យើងខ្ញុំនឹងខិតខំឲ្យអស់ពីសមត្ថភាព និងកម្លាំងកាយចិត្ត ដើម្បីសិក្សាស្រាវជ្រាវពីប្រធានបទខាងលើ ប្រកបដោយគតិបណ្ឌិតខ្ពស់បំផុត។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម**....................១

## ជំពូកទី១

## លក្ខណៈនៃអនីតិសង្វាស

**ផ្នែកទី១៖ សញ្ញាណទូទៅនៃអនីតិសង្វាស**....................៤

១. និយមន័យ....................៦

២. លក្ខខណ្ឌសារធាតុនៃអនីតិសង្វាសនៅកម្ពុជា....................៦

២.១ .ការរស់នៅជាមួយគ្នា....................៧

២.២. សមគ្គសង្វាសតាមព្រឹត្តន័យ....................៧

២.៣. លក្ខណៈស្ថេរភាព និងនិរន្តរភាព....................៧

២.៤. ភេទ....................៨

២.៥. កាតព្វកិច្ចសាមគ្គីគ្នា....................៨

៣.លក្ខខណ្ឌសារធាតុនៃអនីតិសង្វាសនៅជប៉ុន....................៨

៣.១ .ការរស់នៅជាមួយគ្នា....................៩

៣.២. សមគ្គសង្វាសតាមព្រឹត្តន័យ....................៩

៣.៣. លក្ខណៈស្ថេរភាព និងនិរន្តរភាព....................១០

៣.៤. ភេទ....................១០

៣.៥. កាតព្វកិច្ចសាមគ្គីគ្នា....................១០

៤.ភស្តុតាងដើម្បីគាំទ្រលក្ខខណ្ឌសារធាតុនៃអនីតិសង្វាស....................១០

**ផ្នែកទី២៖ ទំនាក់ទំនងអនីតិសង្វាស**....................១១

១. មូលហេតុនៃអនីតិសង្វាសនៅកម្ពុជា....................១១

២. មូលហេតុនៃអនីតិសង្វាសជប៉ុន....................១២

## ជំពូកទី២

## អានុភាពក្នុងអំឡុងពេលរួមអនីតិសង្វាស

**ផ្នែកទី១៖ ទំនាក់ទំនងគតិយុត្តដោយប្រៀបធៀបទៅនឹងច្បាប់នៅកម្ពុជា**.....១៤

១. ចំណងញាតិ..........១៤
២. ការប្រើនាមត្រកូលប្តី ឬប្រពន្ធ..........១៤
៣.ការសន្មតបិតុភាព..........១៤
៤.អាហារកាតព្វកិច្ច..........១៥
៥. ទ្រព្យសម្បត្តិប្តី ឬប្រពន្ធ..........១៥
៦.ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តី ឬប្រពន្ធ..........១៦
៧.ទ្រព្យសម្បត្តិដោយឡែក..........១៧
៨. សន្តតិកម្ម..........១៨
៨.១.លក្ខណៈសម្បត្តិអនីតិសង្វាសជនក្នុងការទទួលមតក..........១៨
៨.២.ការទទួលបានទ្រព្យសម្បត្តិនៃសន្តតិកម្ម..........១៨
**ផ្នែកទី២៖ទំនាក់ទំនងគតិយុត្តដោយប្រៀបធៀបទៅនឹងច្បាប់នៅជប៉ុន**..........១៩
១. បង្កើតចំណងញាតិ..........១៩
២. ការប្រើនាមត្រកូលប្តី ឬប្រពន្ធ..........២០
៣. ការសន្មតបិតុភាព..........២០
៤.អាហារកាតព្វកិច្ច..........២០
៥. ទ្រព្យសម្បត្តិប្តី ឬប្រពន្ធ..........២០
៦.ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ និងទ្រព្យសម្បត្តិដោយឡែក..........២១
៧.សន្តតិកម្ម..........២១

## ជំពូកទី៣

## ការរំលាយអនីតិសង្វាស

**ផ្នែកទី១៖ សញ្ញាណនៃការរំលាយអនីតិសង្វាសជប៉ុន-កម្ពុជា**..........២២
១. មូលហេតុនៃការរំលាយអនីតិសង្វាសជប៉ុន-កម្ពុជា..........២២
២. នីតិវិធីនៃការរំលាយអនីតិសង្វាសនៅកម្ពុជា..........២៣
២.១.បណ្តឹង..........២៣
២.២.ដំណើរការនៃនីតិវិធី..........២៤
២.៣.ការវិនិច្ឆ័យសេចក្តី..........២៥

២.៤. ការអនុវត្តជាក់ស្តែងចំពោះអនីតិសង្វាស..............................................២៦
៣.នីតិវិធីនៃការរំលាយអនីតិសង្វាសនៅជប៉ុន..............................................២៦
៣.១.បណ្តឹង..............................................២៦
៣.២.ដំណើរការនៃនីតិវិធី..............................................២៧
៣.៣.ការវិនិច្ឆ័យសេចក្តី..............................................២៧
៣.៤. ការអនុវត្តជាក់ស្តែងចំពោះអនីតិសង្វាស..............................................២៨
**ផ្នែកទី២៖ អានុភាពនៃការរំលាយអនីតិសង្វាស**..............................................២៨
១. ករណីនៅកម្ពុជា..............................................២៩
១.១.អំណាចមេបាចំពោះកូន..............................................២៩
១.២.សិទ្ធិនិងកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន..............២៩
១.៣. ការទាមទារផ្នែកទ្រព្យសម្បត្តិ..............................................៣០
ក. កម្មសិទ្ធិអវិភាគ..............................................៣០
ខ. កិច្ចសន្យាក្រុមហ៊ុន..............................................៣១
គ. សេចក្តីចម្រើនឥតហេតុ..............................................៣១
ឃ.ការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន(សន្តតិកម្ម)........................៣២
២.ករណីនៅជប៉ុន..............................................៣២
២.១.អំណាចមេបាចំពោះកូន..............................................៣២
២.២.សិទ្ធិនិងកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន.......៣៣
២.៣.ការទាមទារផ្នែកទ្រព្យសម្បត្តិ..............................................៣៣
ក. កម្មសិទ្ធិអវិភាគ..............................................៣៣
ខ.កិច្ចសន្យាក្រុមហ៊ុន..............................................៣៤
គ.សេចក្តីចម្រើនឥតហេតុ..............................................៣៥
ឃ.ការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន(សន្តតិកម្ម)..................៣៥
**សេចក្តីសន្និដ្ឋាន**..............................................៣៦
**អនុសាសន៍**..............................................៣៨

## ឯកសារយោង

## ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រទេសកម្ពុជា និងជប៉ុន ជាប្រទេសដែលមានអត្ថន័យនៃក្រមរដ្ឋប្បវេណីប្រហាក់ប្រហែលគ្នា គឺដោយសារតែក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាឆ្នាំ២០០៧ ត្រូវបានបង្កើតឡើងក្រោមជំនួយរបស់ប្រទេសជប៉ុន ទើបគេសង្កេតឃើញថាប្រព័ន្ធច្បាប់រដ្ឋប្បវេណីរបស់កម្ពុជា ភាគច្រើនមានភាពស្រដៀងគ្នាទៅនឹងប្រព័ន្ធច្បាប់រដ្ឋប្បវេណីនៃប្រទេសជប៉ុន។ ម្យ៉ាងវិញទៀត ក្រមរដ្ឋប្បវេណីជាផ្នែកមួយដ៏សំខាន់ក្នុងការជួយការពារទៅដល់សហព័ទ្ធទាំងពីរពោលគឺ គ្រប់បុគ្គលទាំងអស់ត្រូវបានការពារដោយច្បាប់។ យ៉ាងណាមិញ ក្រមរដ្ឋប្បវេណីបានចែងពី អាពាហ៍ពិពាហ៍ស្របច្បាប់ ប៉ុន្តែមិនបានបង្ហាញពីអនីតិសង្វាសនោះទេ។ ដូច្នេះអនីតិសង្វាសវាជាបញ្ហាដែលកំពុងតែចោទឡើងសម្រាប់សង្គមខ្មែរ និង ជប៉ុននាពេលបច្ចុប្បន្ន ដោយសារតែពុំមានច្បាប់ណាកំណត់ច្បាស់លាស់នៅឡើយ។ ហើយនៅពេលដែលមានទំនាស់កើតឡើងទាក់ទងទៅនឹងបញ្ហាអនីតិសង្វាសនេះ គឺបង្កឲ្យមានភាពលំបាកត្រង់ចំណុចថាតើគួរយកបញ្ញត្តិច្បាប់ណាមកអនុវត្ត។

អាស្រ័យហេតុនេះហើយទើប បណ្តាលឲ្យក្រុមយើងខ្ញុំ ធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទដែលមានចំណងជើងថា **ប្រៀបធៀបអនីតិសង្វាសកម្ពុជា-ជប៉ុន** ដើម្បីសិក្សាស្វែងយល់ថាតើនៅពេលដែលមានបញ្ហាអនីតិសង្វាសកើតឡើង ប្រទេសជប៉ុនមានបទបញ្ញត្តិណាយកមកដោះស្រាយ ហើយការដោះស្រាយបញ្ហាអនីតិសង្វាសនេះមានលក្ខណៈដូចគ្នា និងខុសគ្នាពីប្រទេសកម្ពុជាយ៉ាងដូចម្តេចខ្លះ។ មួយវិញទៀត ប្រធានបទនេះនឹងអាចចូលរួមចំណែកក្នុងការបំពេញចន្លោះប្រហោងខាងផ្នែកគតិយុត្តក្នុងប្រទេសកម្ពុជាបាន។

សារណានេះត្រូវបានតាក់តែងឡើង ដោយផ្អែកលើការសិក្សាស្រាវជ្រាវជុំវិញវិធានគតិយុត្តលើបញ្ហាអនីតិសង្វាសនៅកម្ពុជា និងជប៉ុន តាមរយៈសារណាឯកសារខ្មែរ បរទេស សាលក្រមខ្មែរនិងបរទេស ព្រមទាំងតាមរយៈអ៊ិនធើណេត ដើម្បីវិភាគស្រាវជ្រាវរកឲ្យឃើញបញ្ហាដែលទាក់ទងនឹង អនីតិសង្វាស ដែលមានដូចជា ការរំលាយអនីតិសង្វាស ការបែងទ្រព្យសម្បត្តិរបស់អនីតិសង្វាសជនជាដើម។ ម្យ៉ាងទៀតយើងក៏បានធ្វើការពិភាក្សា និងសិក្សាស្រាវជ្រាវតាមរយៈឯកសារដែលមានស្រាប់ ជាពិសេសក្រមនិងច្បាប់ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តនាពេលបច្ចុប្បន្ន និងនីតិវិធីមួយចំនួនផងដែរ។

សារណានេះមានសារសំខាន់ណាស់ដល់អ្នកស្រាវជ្រាវ និងអ្នកដែលសិក្សាច្បាប់ ព្រោះសារណានេះជាសារណា ដែលបង្ហាញពីការអនុវត្តផ្នែកគតិយុត្តទៅលើ បុរស ស្ត្រីដែលរស់នៅជាមួយគ្នាដូចប្តីប្រពន្ធតែមិនបានចុះសំបុត្រអាពាហ៍អាពាហ៍ស្របច្បាប់ ហើយបង្កជាបញ្ហាវិវាទនៅពេលដែលការរស់នៅរបស់ពួកគាត់មានភាពមិនចុះសម្រុងគ្នា។ បញ្ហានេះកំពុងតែកើតមានឡើងជាញឹកញាប់

នៅក្នុងសង្គមកម្ពុជាក៏ដូចជាសង្គមជប៉ុន ហើយវានឹងក្លាយជាបញ្ហាកាន់តែធំប្រសិនបើករណីនេះនៅតែបន្តកើតមានច្រើនឡើង ដោយសារតែគ្មានច្បាប់ ឬ បទដ្ឋានគតិយុត្តណាកំណត់អំពីករណីអនីតិសង្វាសនេះនៅឡើយ។ មួយវិញទៀតវាក៏ជាបញ្ហាដែលអ្នកច្បាប់កំពុងធ្វើការពិភាក្សាថា គួរយកទៅអនុវត្តប្រដូចទៅនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ឬយ៉ាងណា។

ការរស់នៅក្នុងភាពជាអនីតិសង្វាសមានផលលំបាកជាច្រើននៅពេលដែលមានទំនាស់កើតឡើងរវាងអនីតិសង្វាសជនដែលច្បាប់ពិបាកនឹងការពារជនរងគ្រោះ។ ដូចនេះយើងនឹងសិក្សាលំអិតពីនីតិវិធី និងចំណុចជាបញ្ហាមួយចំនួនរបស់កម្ពុជា និង ជប៉ុន ដូចខាងក្រោម៖

- ការបង្កើតអនីតិសង្វាស
- ការផ្តាច់សមគ្គសង្វាស(សុំបញ្ជាក់នត្ថភាពនៃអាពាហ៍ពិពាហ៍)
- ការបែងចែកទ្រព្យសម្បត្តិ និងអំណាចមេបាទៅលើកូន។

ដើម្បីឆ្លើយតបទៅនឹងដំណោះស្រាយនៃបញ្ហាខាងលើនេះឲ្យបានក្បោះក្បាយនោះយើងខ្ញុំបានបង្កើតជាចំណោទបញ្ហាចំនួន៤គឺ

១.តើអ្វីទៅជាអនីតិសង្វាស?

២.តើការរំលាយអនីតិសង្វាសត្រូវអនុវត្តតាមនីតិវិធីណា?

៣.តើការបែងចែកទ្រព្យត្រូវបានយកមកអនុវត្តយ៉ាងដូចម្តេច?

៤.តើអ្នកណាជាអ្នកដែលមានអំណាចមេបាទៅលើកូន?

សារៈសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះគឺជាគំនិតថ្មីមួយដែលយើងបានប្រមូលមកនូវពត៌មានដែលចាំបាច់ក្នុងការថែរក្សា និងជួយលើកស្ទួយដល់ការអភិវឌ្ឍច្បាប់នៅក្នុងសង្គមកម្ពុជា ជាពិសេសគឺនីតិវិធីរបស់កម្ពុជា និង ជប៉ុន ចំពោះបញ្ហាអនីតិសង្វាសនេះមានភាពខុសគ្នាក៏ដូចជាដូចគ្នាយ៉ាងណាខ្លះ និងស្វែងរកនូវចន្លោះប្រហោងដែលកម្ពុជាមិនទាន់បានអនុវត្ត។

គោលបំណងនៃការសិក្សាស្រាវជ្រាវប្រធានបទអនីតិសង្វាសនេះ គឺផ្តោតសំខាន់ទៅលើបញ្ហាការរំលាយអនីតិសង្វាសដែលកើតឡើងនៅក្នុងសង្គមកម្ពុជា និង ជប៉ុន។ នីតិវិធីនៃការដោះស្រាយជម្លោះក្នុងប្រព័ន្ធតុលាការក្នុងរឿងការរំលាយអនីតិសង្វាស ដើម្បីរកឲ្យឃើញពីស្ថានភាពជាក់ស្តែងនៃអានុភាពនៃការរំលាយ និងឈានដល់ការបែងចែកទ្រព្យសម្បត្តិស្របតាមច្បាប់ មិនតែប៉ុណ្ណោះក៏បានបង្ហាញពីការបង្កើតអនីតិសង្វាស និង អានុភាពផ្សេងៗនៃសិទ្ធិ កាតព្វកិច្ចលើទ្រព្យសម្បត្តិផងដែរ។

សារណានេះចែកចេញជា៣ជំពូក។ ជំពូកទី១ រៀបរាប់ពីសញ្ញាណទូទៅនៃអនីតិសង្វាស និងទំនាក់ទងរបស់អនីតិសង្វាសជន។ នៅក្នុងជំពូកនេះផងដែរ ក៏បានរៀបរាប់ពី អត្ថន័យរបស់អនីតិ

សង្វាស លក្ខខណ្ឌនៃការរស់នៅជាអនីតិសង្វាស ក៏ដូចជាមូលហេតុដែលបណ្តាលឲ្យកើតមានជាអនីតិសង្វាស របស់កម្ពុជា និងជប៉ុនជាដើម។ ចំណែកជំពូកទី២ និយាយអំពីអានុភាពក្នុងអំឡុងពេលរួមអនីតិសង្វាសនៅ កម្ពុជា និងជប៉ុន ដែលទាក់ទងទៅនឹង ទំនាក់ទំនងផ្នែកគតិយុត្តរបស់អនីតិសង្វាសមានអ្វីខ្លះដែលដូចគ្នាទៅនឹងអាពាហ៍ពិពាហ៍ស្របច្បាប់ឬខុសគ្នា។ រីឯជំពូកទី៣វិញរៀបរាប់អំពីការរំលាយអនីតិសង្វាស ដែលកម្ពុជានិងជប៉ុន កំពុងតែអនុវត្តនាពេលបច្ចុប្បន្ននេះ។

ដែនកំណត់ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះគឺធ្វើការផ្តោតសំខាន់និងស៊ីជម្រៅលើ អានុភាពក្នុងអំឡុងពេលរួមអនីតិសង្វាស និងការរំលាយអនីតិសង្វាសប៉ុណ្ណោះ។ ដែលក្នុងនោះយើងខ្ញុំក៏បានបកស្រាយបន្ថែមនូវផ្នែកផ្សេងៗមួយចំនួនផងដែរ។

# ជំពូកទី១៖

# លក្ខណៈនៃអនីតិសង្វាស

# ជំពូកទី១៖ លក្ខណៈនៃអនីតិសង្វាស

ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ មិនបានឲ្យនិយមន័យ អាពាហ៍ពិពាហ៍នោះទេ។ ប៉ុន្តែស្របទៅតាមមាត្រា៣ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារបានឲ្យនិយមន័យអាពាហ៍ពិពាហ៍ថា គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងនារីម្នាក់ដែលពួកគាត់បានប្តេជ្ញាថាខ្លួន នឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ។ ផ្ទុយទៅវិញ អនីតិសង្វាស ជាចំនងក្រៅគតិយុត្តដែលបុរសនិងស្ត្រីរស់នៅជាមួយគ្នាដូចបុរសនិងស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ដែរ។ ប្រសិនបើយើងមើលតែពីខាងក្រៅទៅយើងមិនអាចដឹងថាតើការរួមរស់របស់គូភរិយាណា ជាអនីតិសង្វាស និងគូភរិយាណាជាសហព័ទ្ធស្របច្បាប់នោះទេ។ ដូច្នេះហើយជាបន្ទាប់មកនេះយើងនឹងសិក្សាទៅលើសញ្ញាណទូទៅនៃអនីតិសង្វាសនៅផ្នែកទី១ ព្រមទាំងទំនាក់ទំនងរបស់អនីតិសង្វាសនៅផ្នែកទី២ដែលមានរៀបរាប់ដូចតទៅ៖

## ផ្នែកទី១៖ សញ្ញាណទូទៅនៃអនីតិសង្វាស

តាំងពីសម័យបុរាណរហូតមកដល់បច្ចុប្បន្នកាលនេះ ការរស់នៅរបស់ប្រជាជនខ្មែរ ក៏ដូចជាការរស់នៅរបស់ប្រជាជននៅលើពិភពលោកទាំងមូល ដោយសារតែការវិវត្តនៃការរស់នៅពីសម័យមួយទៅសម័យមួយ យើងឃើញថាមានការផ្លាស់ប្តូរទាំងបរិបទសង្គម និងការរស់នៅក្នុងសង្គមគ្រួសារ ជាក់ស្តែងនៅក្នុងប្រវត្តិសាស្ត្រ ដែលបាននិយាយពីការរស់នៅរបស់ប្រជាជន ពីសម័យមុនៗដូចជាការជ្រើសរើសគូស្រករ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការទទួលបន្ត មតិកជាដើម។

ម្យ៉ាងក្នុងសង្គមកម្ពុជា និងជប៉ុន ប្រពៃណី ទំនៀមទំលាប់ និងសាសនា គឺជាផ្នែកដ៏សំខាន់សម្រាប់មនុស្សគ្រប់រូប។ ក្នុងនោះដែរ អាពាហ៍ពិពាហ៍រវាងជនប្រុស-ស្រី តែងតែត្រូវបានប្រារព្ធឡើងតាមសាសនាប្រពៃណី និងទំនៀមទំលាប់តាំងពីបុរាណ។ ដោយសារតែកត្តានេះហើយទើបជាហេតុនាំឲ្យការរស់នៅជាប្តីប្រពន្ធកើតឡើងច្រើនតាមរយៈប្រពៃណី ទំនៀមទំលាប់និងមានបន្តរហូតមកដល់បច្ចុប្បន្ននេះ។ មួយវិញទៀតក៏មានប្តីប្រពន្ធមួយចំនួនដែលរស់នៅជាមួយគ្នា ដូចប្តីប្រពន្ធគេផ្សេងទៀតដែរ ក៏ប៉ុន្តែការរស់នៅរបស់ពួកគាត់មិនបានគោរពនូវទម្រង់អាពាហ៍ពិពាហ៍ដែលច្បាប់បានកំណត់នោះទេ។ ដែលការរស់នៅបែបនេះគេហៅថាការរស់នៅជាអនីតិសង្វាស។

ជាគោលការណ៍ កាតព្វកិច្ចដែលមានប្រភពខុសគ្នាមិនបានបង្កើតអានុភាពគតិយុត្តដូចគ្នានោះទេ។ ជាក់ស្តែងអនីតិសង្វាស គឺជាប្រភេទចំណងក្រៅគតិយុត្តដែលកើតចេញមកពីបាតុភូតសង្គម និងមិនបង្កើតអានុភាពគតិយុត្តដូចជា អាពាហ៍ពិពាហ៍ដែលជាប្រភេទកិច្ចសន្យាឱឡារិកនោះទេ។ យ៉ាងណាមិញ អនីតិសង្វាសនៅក្នុងស្ថានភាពជាក់ស្តែងយើងឃើញថា មានការរស់នៅជាមួយ

គ្នាពិតដូចជាប្ដីប្រពន្ធស្របច្បាប់។ ប៉ុន្តែអាពាហ៍ពិពាហ៍ស្របច្បាប់គឺស្ថិតក្នុងកិច្ចសន្យាឱឡារិក ដូចនេះវាភ្ជាប់ទំនាក់ទំនងគតិយុត្តពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត ហើយគូភាគីនៃកិច្ចសន្យានេះត្រូវតែគោរពឲ្យបាននូវលក្ខខណ្ឌមួយចំនួនដែលច្បាប់តម្រូវ បើពុំនោះទេត្រូវទទួលទណ្ឌកម្មដោយការលុបចោល ឬមោឃភាពនូវចំណងអាពាហ៍ពិពាហ៍នោះ។ ផ្ទុយទៅវិញអនីតិសង្វាសជាព្រឹត្តិការណ៍ក្រៅគតិយុត្ត ដែលតម្រូវឲ្យមានលក្ខខណ្ឌនៃការបង្កើតរបស់វា តែមិនមែនជាលក្ខខណ្ឌតឹងរឹងដូចអាពាហ៍ពិពាហ៍នោះទេ។ អនីតិសង្វាសជាការសម្ដែងឆន្ទៈសេរី ហើយវាមានសុពលភាព ដោយមិនទាមទារឲ្យបុគ្គលដែលសម្ដែងនោះទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួននោះទេ ។

តាមការពិតទៅនៅកម្ពុជា និងជប៉ុន អនីតិសង្វាស បានកើតឡើងដោយសារតែ ការមិនគោរពលក្ខខណ្ឌនៃទម្រង់អាពាហ៍ពិពាហ៍។ ដូចដែលបានរៀបរាប់មកនេះ ដោយសារតែមានមតិមួយចំនួនគិតថា អាពាហ៍ពិពាហ៍ឈរលើលក្ខខណ្ឌប្រពៃណី គឺមានភាពដូចគ្នាទៅនឹងអាពាហ៍ពិពាហ៍ដែលឈរលើមូលដ្ឋានគតិយុត្ត ទើបជាហេតុបណ្ដាលឲ្យមានអនីតិសង្វាសនេះកើតឡើង ។

យ៉ាងណាមិញអនីតិសង្វាសក៏ត្រូវគោរពលើលក្ខខណ្ឌនៃការបង្កើតរបស់វាមួយច្បាស់លាស់ បើទោះបីជាវាគ្មានបទដ្ឋានគតិយុត្តណាមួយកំណត់ច្បាស់លាស់ក៏ដោយ។

ផ្អែកតាមលក្ខខណ្ឌដែលទាមទារខាងលើនេះជាគោលការណ៍ អនីតិសង្វាសមិនមានរបបគតិយុត្តរបស់វាច្បាស់លាស់ណាមួយ ដែលដូចគ្នាជាមួយអានុភាពគតិយុត្តរបស់អាពាហ៍ពិពាហ៍នោះទេ។ ការយកបទបញ្ញត្តិស្ដីពីអាពាហ៍ពិពាហ៍មកអនុវត្តនៅក្នុងរឿងអនីតិសង្វាស វាជាការបំពានទៅនឹងគោលការណ៍ទូទៅនៃការបែងចែកប្រភពនៃកាតព្វកិច្ច។ តែក្នុងស្ថានភាពមួយចំនួនដើម្បីធានាឲ្យបាននូវភាពយុត្តិធម៌រវាងគូភាគីនៃអនីតិសង្វាស គេបានយករបបគតិយុត្តណាមួយទៅអនុវត្តក្នុងសញ្ញាណនៃគតិយុត្តណាមួយទៀត ដោយមិនឲ្យប្រាសចាកពីគោលការណ៍ទូទៅ ឬគោលបំណងរបស់វាឡើយ។ តួយ៉ាងអនីតិសង្វាសមិនមានអភ័យឯកសិទ្ធិគ្រួសារ[1] និងសិទ្ធិមួយចំនួននោះទេ។ អនីតិសង្វាសមិនបង្កើតឲ្យមានប្រព័ន្ធទ្រព្យសម្បត្តិរួមនិងទ្រព្យសម្បត្តិដោយឡែកដូចនីតិសង្វាសនោះទេ។ ដូច្នេះវិធីបកស្រាយច្បាប់ត្រូវបកស្រាយដោយប្រុងប្រយ័ត្នបំផុតក្នុងរឿងព្រហ្មទណ្ឌ[2] និងរដ្ឋប្បវេណីដើម្បីធានានូវការគោរពគោលការណ៍នីត្យានុកូលភាព និង ការបកស្រាយច្បាប់ព្រហ្មទណ្ឌកម្ពុជា។ [3] ជាងនេះទៅទៀតការអនុវត្តតាមនីតិវិធីបកស្រាយបែបនេះតម្រូវឲ្យមានការបែងចែកនិងស្គាល់ឲ្យបានច្បាស់លាស់នៃអានុភាពរបស់អនីតិសង្វាសនៅក្នុងអំឡុងពេលអត្ថិភាពរបស់វា ក៏ដូច

[1] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខនស/រកម/១១០៩/០២២,២០១០មាត្រា៥៥

[2] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខនស/រកម/១១០៩/០២២,២០១០ មាត្រា៥

[3] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខនស/រកម/១១០៩/០២២,២០១០មាត្រា៣

ជាក្រោយការរំលាយអនីតិសង្វាសហើយព្រមទាំងពិនិត្យមើលដោយប្រុងប្រយ័ត្នលើទិដ្ឋភាពគតិយុត្តផ្សេងៗទៀតដែលនៅជុំវិញវា។

**១. និយមន័យ**

អនីតិសង្វាសមិនត្រូវបានច្បាប់កម្ពុជា និងច្បាប់ជប៉ុនឲ្យនិយមន័យនោះទេ តែត្រូវបានគេព្យាយាមផ្ដល់និយមន័យថា ជាស្ថានភាពរបស់បុរស និង នារីដែលរួមរស់នៅជាមួយគ្នាដូចប្តីប្រពន្ធមានខាន់ស្លា ប៉ុន្តែឥតមានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។ [4]មួយវិញទៀត នៅពេលដែលភាគីនៃអាពាហ៍ពិពាហ៍មិនបានបំពេញលក្ខណ្ឌច្បាប់ អាពាហ៍ពិពាហ៍ស្របច្បាប់មិនបានកើតឡើងនោះទេ ប៉ុន្តែអាពាហ៍ពិពាហ៍ដែលមានលក្ខណៈជាក់ស្ដែង ទៅតាមប្រពៃណីទំនៀមទំលាប់នៃសង្គមអាចឡើងបាន ករណីនេះយើងហៅថា អនីតិសង្វាស (សមគ្គសង្វាសតាមព្រឹត្តន័យ)។[5]

ជាទ្រឹស្ដីអាពាហ៍ពិពាហ៍ដែលមិនបានគោរពតាមបញ្ញត្តិក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ [6] និងក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០[7] នឹងមិនត្រូវចាត់ទុកជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ប៉ុន្តែការមិនអនុវត្តនៅបញ្ញត្តិក្រមរដ្ឋប្បវេណីខាងលើនេះមិនអាចធ្វើឲ្យចំណងអាពាហ៍ពិពាហ៍នោះក្លាយទៅជាអនីតិសង្វាសជាស្វ័យប្រវត្តិនោះទេ។ នៅក្នុងន័យនេះមានន័យថាការរស់នៅជាមួយគ្នាត្រឹមរយៈពេលខ្លីមិនមែនជាអនីតិសង្វាសឡើយ ប៉ុន្តែក្នុងនេះដែរក៏មានការបកស្រាយខុសៗគ្នាជាច្រើនដោយពុំមានបទដ្ឋានណាមួយកំណត់ឲ្យបានជាក់លាក់នៅឡើយទេ។ ដូច្នេះអនីតិសង្វាស គឺជាការមិនបានបំពេញនៅលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍។ អាពាហ៍ពិពាហ៍ស្របច្បាប់ គឺភាគីនៃចំណងអាពាហ៍ពិពាហ៍បានបំពេញលក្ខខណ្ឌសារធាតុដូចជា នីតិជន បុរស និងនារីជាអាទិ៍ និងបានបំពេញលក្ខខណ្ឌទម្រង់ ដូចជា ទី១ ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទី២ ការជូនដំណឹងជាសាធារណៈ(ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍) ទី៣ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ទី៤ ចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន[8] ហើយសំបុត្រអាពាហ៍ពិពាហ៍ គឺជាភស្តុតាងបញ្ជាក់អំពីអាពាហ៍ពិពាហ៍។

**២. លក្ខខណ្ឌសារធាតុនៃអនីតិសង្វាសនៅកម្ពុជា**

នៅប្រទេសកម្ពុជា ពាក្យ **អនីតិសង្វាស** ត្រូវបានគេប្រើប្រាស់នៅក្នុងច្បាប់នានាជាក់ស្ដែងនៅក្នុងមាត្រា២២២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៧ ដោយមិនបានកំណត់របបគតិយុត្តរបស់វាឲ្យបាន

---

[4] សាស្ត្រាចារ្យ ចក សម្បត្តិ (អនីតិសង្វាស) ទំព័រទី៣ (២០១៤)

[5] មេធាវី អ៊ីវ ប៉ូលី និង ថៅប៊ុនហួន,ការធ្វើបទបង្ហាញរបស់

[6] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧, ចាប់ពីមាត្រា៩៤៨ ដល់មាត្រា៩៥៧

[7] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០, ចាប់ពីមាត្រា ៧៣១ ដល់មាត្រា ៧៤១

[8] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា៩៥៥ កថាខណ្ឌទី១ និងក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ មាត្រា៧៣៩

ច្បាស់លាស់នោះទេ។ ភាគីនៃទំនាក់ទំនងនេះ ម្ខាងហៅថាអនីតិសង្វាសី និងម្ខាងទៀតហៅថា អនីតិសង្វាសនី (តាមសន្ទានុក្រមបារាំងខ្មែរ) តែក្រមព្រហ្មទណ្ឌមាត្រា២២២ ប្រើពាក្យ អនីតិសង្វាសជន។ ដូចនេះ ការប្រើពាក្យ អនីតិសង្វាសជនគឺវាស្របជាមួយបញ្ញត្តិច្បាប់។[9]

អនីតិសង្វាស និងអាពាហ៍ពិពាហ៍ស្របច្បាប់មានចំណុចខុសគ្នាត្រង់អត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍។ រីឯអនីតិសង្វាស និងកំជាប់ពាក្យមានចំណុច ខុសគ្នាត្រង់កំជាប់ពាក្យមានឆន្ទៈនឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត មានន័យថាមិនទាន់រៀបអាពាហ៍ពិពាហ៍ជាក់ស្តែងនៅឡើយ។ [10] អនីតិសង្វាសនិងសង្សា ឬគូដណ្តឹង គឺមានលក្ខណៈស្រពិចស្រពិលស្ថិតនៅត្រង់ថាតើមានជីវភាពរួមគ្នា និងមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ឬយ៉ាងណា?

### ២.១ ការរស់នៅជាមួយគ្នា

អនីតិសង្វាស និងអាពាហ៍ពិពាហ៍ស្របច្បាប់ មានការរួមរស់ជាលក្ខណៈដូចជាប្តីប្រពន្ធដូចគ្នា។ គ្រាន់តែ លក្ខណៈនៃការរស់នៅជាមួយគ្នារបស់អនីតិសង្វាស គឺជាការរស់នៅក្នុងសង្គម ក្រោមដំបូលផ្ទះតែមួយនិងប្រើដំណើរជីវិតរួមគ្នាមួយ ប៉ុន្តែ មិនត្រូវបានទទួលស្គាល់ដោយច្បាប់ឡើយ។ [11] លក្ខខណ្ឌនៃការរស់នៅជាមួយគ្នាជាលក្ខខណ្ឌកំណត់ពីលក្ខណៈស្ថេរភាពនិង និរន្តរភាព មានន័យថាវានឹងមិនមែនជាអនីតិសង្វាសឡើយ បើបានរស់នៅជាមួយគ្នាត្រឹមរយៈពេលខ្លីនោះ។

### ២.២. សមគ្គសង្វាសតាមប្រព្រឹត្តន័យ

អនីតិសង្វាស គឺជាសមគ្គសង្វាសតាមព្រឹត្តន័យមួយ ដែលមានភាពខុសគ្នាពីអាពាហ៍ពិពាហ៍ដូច្នេះវាបង្កើតអានុភាពគតិយុត្តដោយឡែក ខុសពីអាពាហ៍ពិពាហ៍ស្របច្បាប់។ ម៉្យាងទៀត អនីតិសង្វាស គឺត្រូវបានបែងចែកដាច់ពីអាពាហ៍ពិពាហ៍ពីព្រោះអាពាហ៍ពិពាហ៍ជាលិខិតគតិយុត្ត ឬសកម្មភាពគតិយុត្តច្បាស់លាស់មួយ រីឯអនីតិសង្វាសគឺជាសមគ្គសង្វាសតាមប្រព្រឹត្តន័យមួយ ដែលវាត្រូវបានបង្កើតដោយឆន្ទៈសេរីរបស់គូភាគី និងរំលាយទៅវិញដោយឆន្ទៈសេរីផងដែរ ។

### ២.៣.លក្ខណៈស្ថេរភាព និង និរន្តរភាព

ទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ដូចជាអនីតិសង្វាសជាដើម លេចឡើងនូវភាពចម្រុះច្រើនបែបដែលខ្លះ ស្ថិតជានិរន្ត ខ្លះរយៈពេលខ្លី ខ្លះលាក់បាំង ខ្លះបើកចំហជាសាធារណៈ ខ្លះសង្គមទទួលស្គាល់ ឬខ្លះទៀតសង្គមមិនទទួលស្គាល់។ ក៏ប៉ុន្តែ ការទាក់ទងគ្នាម្តងម្កាល មិនបង្កើតជាអនីតិ

[9] ចក សម្បត្តិ (អនីតិសង្វាស) ទំព័រទី១៧ (២០១៤)

[10] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា៩៨៤

[11] អ៊ុឈីដា តីផុ ,នីតិរដ្ឋប្បវេណីភាគទី៤ ស្តីពីញាតិនិងសន្តតិកម្ម បោះពុម្ពលើកទី៦ ឆ្នាំ២០០៤ ទំព័រ១៤១។ 内田 貴著『民法 4 親族・相続』第 6 版（有斐閣、2004 年）141 項。

សង្វាសនោះទេ ពីព្រោះថាអនីតិសង្វាស ត្រូវការអំឡុងពេលវេលាសមស្របមួយ ពោលអនីតិសង្វាស គឺជាស្ថានភាពនៃព្រឹត្តិការណ៍ដែលមានរយៈពេលយូរជានិរន្តរ។[12]ប្រសិនបើមានការរួមរស់នៅជាមួយគ្នាត្រឹមរយៈពេលខ្លីនោះនឹងមិនចាត់ទុកជាអនីតិសង្វាសទេ។

### ២.៤. ភេទ

នៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ មាត្រា៩៤៨ បានទទួលស្គាល់តែអាពាហ៍ពិពាហ៍ដែលមានភេទផ្ទុយគ្នាតែប៉ុណ្ណោះ ប៉ុន្តែភាពជាក់ស្តែងគេសង្កេតឃើញមានការកើតឡើងនៃការរស់នៅជាមួយគ្នា និងការយកគ្នាជាប្តីប្រពន្ធរវាងមនុស្សដែលមានភេទដូចគ្នា ដោយសារការទទួលស្គាល់នូវសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣។

តើភេទដូចគ្នាអាចបង្កើតជាអនីតិសង្វាសបានឬទេ?

នៅក្នុងក្រមរដ្ឋប្បវេណី ប្តី ប្រពន្ធ ត្រូវតែមានភេទផ្ទុយគ្នាទើបអាចរៀបអាពាហ៍ពិពាហ៍បានដោយស្របច្បាប់ ហេតុដូចនេះភេទដូចគ្នា និងត្រូវពិចារណាថាតើជាអនីតិសង្វាស ឬស្ថិតក្នុងស្ថានភាពផ្សេងទៀត។

### ២.៥. កាតព្វកិច្ចសាមគ្គីគ្នា

ប្រសិនបើភាគី នៃអនីតិសង្វាសបានចំណាយ ដើម្បីជីវភាពរស់នៅរួម ការអប់រំ ការថែទាំ ការព្យាបាលកូនជាអាទិ៍ ឬសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ ឬកាតព្វកិច្ចផ្សេងៗ ដែលភាគីនៃអនីតិសង្វាស បានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ជាមួយ នឹងម្ចាស់បំណុល ឬតែភាគីតែម្ខាង ប៉ុន្តែម្ខាងទៀតបានយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅក្នុងអំឡុងពេលអនីតិសង្វាស ត្រូវចាត់ទុកជាកាតព្វកិច្ចសាមគ្គី[13] របស់ភាគីនៃអនីតិសង្វាស។

## ៣.លក្ខខណ្ឌសារធាតុនៃអនីតិសង្វាសនៅជប៉ុន

នៅប្រទេសជប៉ុន **អនីតិសង្វាស** ត្រូវបានគេចែងនៅក្នុងច្បាប់ដែលទាក់ទងទៅនឹងសុខមាលភាពសង្គម និងប្រាក់សោធននិវត្តន៍ ជាដើម មានចំណុចជាច្រើនដែលប្រព្រឹត្តកម្ម[14]ចំពោះប្តីប្រពន្ធនៃអនីតិសង្វាស ដូចគ្នាទៅនឹងប្រព្រឹត្តកម្មចំពោះប្តីប្រពន្ធដែលមានចំណងអាពាហ៍ពិពាហ៍តាមច្បាប់ដែរ។[15]

[12] ចក សម្បត្តិ (អនីតិសង្វាស) ទំព័រទី១៩ (២០១៤)

[13] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា ៩៧៥

[14] ប្រព្រឹត្តកម្ម គឺជាការប្រើប្រាស់

[15] ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ (សេចក្តីផ្តើមនីតិរដ្ឋប្បវេណី) ទំព័រទី១៤៩ (២០១១)

បន្ថែមពីនេះទៅទៀត នៅប្រទេសជប៉ុន អនីតិសង្វាស និងអាពាហ៍ពិពាហ៍ស្របច្បាប់មានចំណុច ខុសគ្នាត្រង់អត្ថិភាពនៃការចុះសំបុត្រអាពាហ៍ពិពាហ៍។[16] ប៉ុន្តែ ប្រទេសជប៉ុនមិនបានកំណត់ពីភាពខុសគ្នារវាង អនីតិសង្វាស និងកំជាប់ពាក្យនោះទេ ដោយសារតែក្រមរដ្ឋប្បវេណីនៃប្រទេសជប៉ុនមិនបានកំណត់ពីកំជាប់ពាក្យឡើយ។

នៅប្រទេសជប៉ុន ទាក់ទងទៅនឹងការបង្កើតអនីតិសង្វាសមិនទាមទារតម្រូវឲ្យបំពេញលក្ខខណ្ឌដូចជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ជាទូទៅ ទោះបីជាអនីតិជន ឬអំឡុងពេលហាមមិនឲ្យរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏អនីតិសង្វាស អាចបង្កើតឡើងផងដែរ។ [17] មួយវិញទៀត អនីតិសង្វាសអាចបង្កើតបាន ក្នុងករណីមួយចំនួយដូចជា បុគ្គលម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មានទំនាក់ទំនងអនីតិសង្វាសជាមួយនឹងជនផ្សេងទៀតក្រៅពីសហព័ទ្ធរបស់ខ្លួន ប៉ុន្តែ សហព័ទ្ធស្របច្បាប់ត្រូវបានការពារ។ [18] អនីតិសង្វាសរវាងញាតិ មិនអាចបង្កើតបានឡើយ (អាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬញាតិពន្ធ)។[19]

### ៣.១ ការរស់នៅជាមួយគ្នា

នៅប្រទេសជប៉ុន អនីតិសង្វាស និងអាពាហ៍ពិពាហ៍ស្របច្បាប់ មានការរួមរស់ជាលក្ខណៈដូចជាប្តីប្រពន្ធដែរ។ គ្រាន់តែ លក្ខណៈនៃការរស់នៅជាមួយគ្នារបស់អនីតិសង្វាស គឺជាការរស់នៅក្នុងសង្គម ក្រោមដំបូលផ្ទះតែមួយនិងប្រើដំណើរជីវិតរួមគ្នាមួយ ប៉ុន្តែមិនត្រូវបានទទួលស្គាល់ដោយច្បាប់ឡើយ។[20]លក្ខខណ្ឌនៃការរស់នៅជាមួយគ្នាជាលក្ខខណ្ឌកំណត់ពីលក្ខណៈស្ថេរភាពនិង និរន្តរភាព មានន័យថាមិនមែនជាអនីតិសង្វាសឡើយ បើបានរស់នៅជាមួយគ្នាត្រឹមរយៈពេលខ្លីនោះ។

### ៣.២. សមគ្គសង្វាសតាមប្រព្រឹត្តន័យ

នៅប្រទេសជប៉ុន អនីតិសង្វាស គឺជាសមគ្គសង្វាសតាមព្រឹត្តន័យមួយ ជាចំណងរបស់បុរសស្ត្រីមួយគូ ដែលមានភាពខុសគ្នាពីអាពាហ៍ពិពាហ៍ ដូច្នេះវាបង្កើតអានុភាពគតិយុត្តដោយឡែក ខុសពីអាពាហ៍ពិពាហ៍ស្របច្បាប់ផងដែរ។ ម្យ៉ាងទៀត អនីតិសង្វាស គឺត្រូវបានបែងចែកដាច់ពី

---

[16] ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ មាត្រា៧៣៩

[17] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧,មាត្រា៩៤៨ និង៩៥៣, ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ មាត្រា៧៣១

[18] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា៩៤៩, ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ មាត្រា៧៣២

[19] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា៩៥១,៩៥២ ,ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ មាត្រា៧៣៣

[20] អ៊ីឈីដា គីឆុ ,នីតិរដ្ឋប្បវេណីភាគទី៤ ស្តីពីញាតិនិងសន្តតិកម្ម បោះពុម្ពលើកទី៦ ឆ្នាំ២០០៤ ទំព័រ១៤១។ 内田 貴著『民法 4 親族・相続』第 6 版（有斐閣、2004 年）141 項。

អាពាហ៍ពិពាហ៍ពីព្រោះអាពាហ៍ពិពាហ៍ជាលិខិតគតិយុត្ត ឬសកម្មភាពគតិយុត្តច្បាស់លាស់មួយ រីឯអនីតិសង្វាសគឺជាសមគ្គសង្វាសតាមប្រព្រឹត្តន័យមួយ ដែលវាត្រូវបានបង្កើតដោយឆន្ទៈសេរីរបស់គូភាគី និងរំលាយទៅវិញដោយឆន្ទៈសេរីផងដែរ ។

**៣.៣. លក្ខណៈស្ថេរភាព និង និរន្តរភាព**

ចំពោះលក្ខណៈស្ថេរភាព និង និរន្តភាពរបស់អនីតិសង្វាសនៅប្រទេសជប៉ុន គឺវាលេចឡើងនូវភាពចម្រុះច្រើនបែបដែលខ្លះ ស្ថិតជានិរន្ត ខ្លះរយៈពេលខ្លី ខ្លះលាក់បាំង ខ្លះបើកចំហជាសាធារណៈ ប៉ុន្តែ នៅប្រទេសជប៉ុន អនីតិសង្វាស គឺមិនត្រូវបានសង្គមទទួលស្គាល់ឡើយ។ ករណីមានការទាក់ទងគ្នាម្តងម្កាល មិនបង្កើតជាអនីតិសង្វាសនោះទេ ពីព្រោះថាអនីតិសង្វាស ត្រូវការអំឡុងពេលវេលាសមស្របមួយ ពោលអនីតិសង្វាសគឺជាស្ថានភាពនៃព្រឹត្តិការណ៍ដែលមានរយៈពេលយូរជានិរន្ត។[21]ប្រសិនបើមានការរួមរស់នៅជាមួយគ្នាត្រឹមរយៈពេលខ្លីក៏មិនចាត់ទុកជាអនីតិសង្វាសទេ។

**៣.៤. ភេទ**

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា៧៣១ បានទទួលស្គាល់តែអាពាហ៍ពិពាហ៍ដែលមានភេទផ្ទុយគ្នាតែប៉ុណ្ណោះ។ ដូច្នេះ នៅប្រទេសជប៉ុន មិនទទួលស្គាល់ ភេទដូចគ្នាជាអនីតិសង្វាសនោះទេ ដោយហេតុថាគេចាត់ទុកវា ផ្ទុយសណ្តាប់ធ្នាប់សាធារណៈ ទំនៀមទំលាប់ល្អរបស់សង្គម និងប្រពៃណីរបស់សង្គមជាតិជប៉ុន ។[22]

**៣.៥. កាតព្វកិច្ចសាមគ្គីគ្នា**

ទាក់ទងនឹងកាតព្វកិច្ចសាមគ្គីគ្នា នៅប្រទេសជប៉ុន ប្រសិនបើភាគី នៃអនីតិសង្វាសបានចំណាយ ដើម្បីជីវភាពរស់នៅរួម ការអប់រំ ការថែទាំ ការព្យាបាលកូនជាអាទិ៍ ឬសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ ឬកាតព្វកិច្ចផ្សេងៗ ដែលភាគី នៃអនីតិសង្វាស បានព្រមព្រៀងគ្នាជាលាយល័ក្ខណ៍អក្សរ ជាមួយ នឹងម្ចាស់បំណុល ឬតែភាគីតែម្ខាង ប៉ុន្តែម្ខាងទៀតបានយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅក្នុងអំឡុងពេលអនីតិសង្វាស ត្រូវចាត់ទុកជាកាតព្វកិច្ចសាមគ្គី[23] របស់ភាគីនៃអនីតិសង្វាស។

**៤. វិធានការដើម្បីគាំទ្រលក្ខខណ្ឌសារធាតុនៃអនីតិសង្វាស**

[21] ចក សម្បត្តិ (អនីតិសង្វាស) ទំព័រទី១៩ (២០១៨)
[22] មេធាវី អ៊ីវ ប៉ូលី និង ចៅប៊ុនហួន,ការធ្វើបទបង្ហាញរបស់
[23] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ ១៩៨០ ចាប់ពីមាត្រា ៩៦១

ការប្រកាសពី នត្ថិភាព[24] នៃអាពាហ៍ពិពាហ៍ ដោយយោងតាមចំណុចដែលបានលើកឡើងខាងលើនេះ ជាមូលដ្ឋានគតិយុត្តអាចនាំឲ្យតុលាការចាត់ទុកថាអាពាហ៍ពិពាហ៍តាមទំនៀមទំលាប់ប្រពៃណីនោះជាអនីតិសង្វាសបាន ។

នៅប្រទេសកម្ពុជាសព្វថ្ងៃការគ្រប់គ្រងលើស្ថិតិប្រជាជននៅមានលក្ខណៈទន់ខ្សោយនៅឡើយ ភាពទន់ខ្សោយនេះបង្កទៅជាផលអវិជ្ជមានផ្នែកគតិយុត្តយ៉ាងខ្លាំង ពីព្រោះថាទោះបីជាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ក៏ដោយ តែបុរសនារី ដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីនោះនឹងទទួលបាននូវសៀវភៅគ្រួសារដោយទទួលស្គាល់ភាពជាប្ដីប្រពន្ធនឹងគ្នា។ ម៉្យាងទៀត សៀវភៅគ្រួសារអាចជា ភស្ដុតាង ដែលបញ្ជាក់អំពីអត្ថិភាពនៃអនីតិសង្វាសបាន។ ប៉ុន្ដែនៅក្នុងបណ្ដឹង[25] មិនតម្រូវឲ្យភាគីដាក់សៀវភៅគ្រួសារមកជូនតុលាការនោះទេ។ តែក្នុងស្ថានភាពជាក់ស្ដែងនៅពេលដែលមានបណ្ដឹងទាមទារផ្ដាច់សមគ្គសង្វាស (សុំបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍) ភាគីទាំងសងខាងភាគច្រើនបានយល់ស្របអំពីការរស់នៅជាមួយគ្នាជាអនីតិសង្វាស ។ ទោះជាយ៉ាងណាក៏ដោយ តុលាការតម្រូវឲ្យភាគីដាក់ភស្ដុតាង ទោះបីជាមានការអះអាងដូចគ្នាក៏ដោយ ។ ដោយយោងទៅតាមការបកស្រាយនៃមាត្រា ១២៣ នៃក្រមរនីតិវិធីដ្ឋប្បវេណីកម្ពុជា ដែលបង្កប់នូវគោលការណ៍សច្ចាធារណ៍តាមតុលាការ។ ក្នុងគ្រប់ករណីតុលាការត្រូវធ្វើនីតិវិធីផ្ទៀងផ្ទាត់លើភស្ដុតាងដែលបានដាក់ជូនមកខ្លួនដោយគូភាគី ទោះបីជាភស្ដុតាងនោះ ជាសម្ដីសារភាពរបស់គូភាគីក៏ដោយ។ ការផ្ទៀងផ្ទាត់នេះ គឺដើម្បីពិនិត្យទៅលើភាពពិតប្រាកដ ភាពត្រឹមត្រូវ និងភាពដែលអាចឲ្យចៅក្រមជឿលើភស្ដុតាងទាំងនោះបាន។

ក្នុងសភាពជាសមគ្គសង្វាសតាមព្រឹត្តន័យ តុលាការត្រូវធ្វើការផ្ទៀងផ្ទាត់តាមគ្រប់មធ្យោបាយផ្សេងៗទៀតដូចជា តាមរយៈការដាក់អាស័យដ្ឋានរួមគ្នា តាមវិញ្ញាបនបត្រម្ចាស់អចលនវត្ថុ តាមការចុះក្នុងប័ណ្ណសំគាល់កម្មសិទ្ធិ តាមការកាន់កាប់អចលនវត្ថុ តាមការបញ្ជាក់ពីមេភូមិ មេឃុំ ឬចៅសង្កាត់ ការដឹងលឺថាបុរស និងនារីនោះពិតជាបានរៀបអាពាហ៍ពិពាហ៍តាមផ្លូវប្រពៃណីពិតប្រាកដមែនជាដើម។

ដោយឡែកនៅប្រទេសជប៉ុនសព្វថ្ងៃ ដោយសារការគ្រប់គ្រងលើស្ថិតិប្រជាជនមានលក្ខណៈរឹងមាំ ទោះបីជាបុរសនារី ដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីក៏ដោយ ក៏ពុំទទួលបាននូវសៀវភៅគ្រួសារដោយទទួលស្គាល់ភាពជាប្ដីប្រពន្ធនឹងគ្នាឡើយ។ ប៉ុន្ដែសម្រាប់តុលាការ ដើម្បីទទួល

[24] នត្ថិភាព គឺភាពគ្មាន

[25] ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦,មាត្រា ៧៥

ស្គាល់ ទំនាក់ទំនងបុរសនារីនោះ ជាអនីតិសង្វាស គឺតុលាការត្រូវធ្វើការផ្ទៀងផ្ទាត់តាមរយៈការដាក់អាស័យដ្ឋានរួមគ្នា តាមវិញ្ញាបនប័ត្រម្ចាស់អចលនវត្ថុតាមរយៈការចុះក្នុងប័ណ្ណសំគាល់កម្មសិទ្ធិ និងតាមរយៈការកាន់កាប់អចលនវត្ថុជាដើម។ [26]

## ផ្នែកទី២៖ ទំនាក់ទំនងអនីតិសង្វាស

### ១. មូលហេតុនៃអនីតិសង្វាសនៅកម្ពុជា

ជាទ្រឹស្តីអាពាហ៍ពិពាហ៍ ដែលមិនអាចគោរពតាមបញ្ញត្តិ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧[27] នឹងមិនត្រូវទុកជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ប៉ុន្តែការមិនអនុវត្តនៅបញ្ញត្តិក្រមរដ្ឋប្បវេណីខាងលើនេះ មិនបង្កើតឲ្យចំណងអាពាហ៍ពិពាហ៍នោះក្លាយទៅជាអនីតិសង្វាសជាស្វ័យប្រវត្តិនោះទេ។ ក្នុងន័យនេះ មានន័យថាការរស់នៅជាមួយគ្នាត្រឹមរយៈពេលខ្លីមិនមែនជាអនីតិសង្វាសឡើយ ប៉ុន្តែក្នុងនេះក៏មានការបកស្រាយខុសៗគ្នាជាច្រើន ដោយពុំមានបទដ្ឋានណាមួយកំណត់ឲ្យបានជាក់លាក់នៅឡើយ។ ដូច្នេះអនីតិសង្វាស គឺជាការមិនបានបំពេញនៅលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍មួយចំនួនដូចខាងក្រោម៖

- **ការមិនគោរពលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍ គឺជាចំណងគតិយុត្ត ដែលមានភាពស្មុគស្មាញ និងមានបុគ្គលពាក់ព័ន្ធជាច្រើន ដែលតម្រូវឲ្យមានការគាំពារជាចាំបាច់។ អាពាហ៍ពិពាហ៍ស្របច្បាប់ គឺភាគីនៃចំណងអាពាហ៍ពិពាហ៍បានបំពេញលក្ខខណ្ឌសារធាតុ ដូចជា នីតិជន, បុរស និង នារីជាអាទិ៍ ព្រមទាំងបានបំពេញលក្ខខណ្ឌទម្រង់ ដូចជា **ទី១** ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ **ទី២** ការជូនដំណឹងជាសាធារណៈ(ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍) **ទី៣** ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ **ទី៤** ចុះបញ្ជីនៅចំពោះមន្ត្រីអាត្រានុកូលដ្ឋាន ហើយសំបុត្រអាពាហ៍ពិពាហ៍ គឺជាភស្តុតាងបញ្ជាក់ពីអាពាហ៍ពិពាហ៍។[28]

នៅពេលភាគី នៃអាពាហ៍ពិពាហ៍មិនអាចបំពេញលក្ខខណ្ឌច្បាប់នោះ អាពាហ៍ពិពាហ៍ស្របច្បាប់មិនអាចកើតឡើងឡើយ ប៉ុន្តែអាពាហ៍ពិពាហ៍លក្ខណៈជាក់ស្តែងតាមប្រពៃណីទំនៀមទំលាប់នៃសង្គមបានកើតឡើងក្នុងករណីនេះ យើងហៅថាអនីតិសង្វាស (សមគ្គសង្វាសតាមព្រឹត្តន័យ) ។

### ២. មូលហេតុនៃអនីតិសង្វាសជប៉ុន

[26] អ៊ីឈីដា គីធុ ,នីតិរដ្ឋប្បវេណីភាគទី៤ ស្តីពីញាតិនិងសន្តតិកម្ម បោះពុម្ពលើកទី៦ ឆ្នាំ២០០៤ ទំព័រ១៥១។ 内田 貴著『民法 4 親族・相続』第 6 版（有斐閣、2004 年）151 項。និងការសំភាសន៍ជាមួយសាស្ត្រាចារ្យជប៉ុន តាម៉ាកាគី
[27] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ ចាប់ពីមាត្រា ៩៤៨ ដល់ មាត្រា ៩៥៧
[28] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៥៥ កថាខណ្ឌទី១

ជាទ្រឹស្តីអាពាហ៍ពិពាហ៍ ដែលមិនអាចគោរពតាមបញ្ញត្តិ ក្រមរដ្ឋប្បវេណីឆ្នាំ ១៩៨០[29] និងមិនត្រូវទុកជាអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ប៉ុន្តែការមិនអនុវត្តនៅបញ្ញត្តិក្រមរដ្ឋប្បវេណីខាងលើនេះ មិនបង្កើតឲ្យចំណងអាពាហ៍ពិពាហ៍នោះក្លាយទៅជាអនីតិសង្វាសជាស្វ័យប្រវត្តិនោះទេ។ ក្នុងន័យនេះ មានន័យថាការរស់នៅជាមួយគ្នាត្រឹមរយៈពេលខ្លីមិនមែនជាអនីតិសង្វាសឡើយ។ មូលហេតុដែលបណ្តាលឲ្យមានអនីតិសង្វាសនៅជប៉ុនមានដូចជា ភាគីនៃអនីតិសង្វាសមិនអាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បានដោយសារស្ថានភាពផ្លូវចិត្ត ឬមានអាយុច្រើនពេក (អាយុ ៧០ឡើងទៅ) មិនចង់មានចំណងផ្លូវច្បាប់ឬមិនចង់ដូរត្រកូល ភាគីនៃអនីតិសង្វាស យឺតយ៉ាវក្នុងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ភាគីនៃអនីតិសង្វាសយល់ថា ការរៀបអាពាហ៍តាមប្រពៃណីមានសារៈសំខាន់ជាងការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ជាអាទិ៍។ ដូច្នេះអនីតិសង្វាស គឺជាការមិនបានបំពេញនៅលក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍មួយចំនួនដូចខាងក្រោមៈ

- **ការមិនគោរពលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍ គឺជាចំណងគតិយុត្ត ដែលមានភាពស្មុគស្មាញ និងមានបុគ្គលពាក់ព័ន្ធជាច្រើន ដែលតម្រូវឲ្យមានការគាំពារជាចាំបាច់។ អាពាហ៍ពិពាហ៍ស្របច្បាប់ គឺភាគីនៃចំណងអាពាហ៍ពិពាហ៍បានបំពេញលក្ខខណ្ឌសារធាតុ ដូចជា នីតិជន បុរស និង នារីជាអាទិ៍ ព្រមទាំងបានបំពេញលក្ខខណ្ឌទម្រង់ ដូចជា**ទី១** ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយស្របតាមការកំណត់នៃច្បាប់ស្តីពីការចុះបញ្ជីគ្រួសារនៃប្រទេសជប៉ុន(មាត្រា២២៤)[30] **ទី២** ការជូនដំណឹងជាសាធារណៈ(ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍)។[31]

នៅពេលភាគី នៃអាពាហ៍ពិពាហ៍មិនអាចបំពេញលក្ខខណ្ឌច្បាប់នោះ អាពាហ៍ពិពាហ៍ស្របច្បាប់មិនអាចកើតឡើងឡើយ ប៉ុន្តែអាពាហ៍ពិពាហ៍លក្ខណៈជាក់ស្តែងតាមប្រពៃណីទំនៀមទំលាប់នៃសង្គមបានកើតឡើងករណីនេះ យើងហៅថាអនីតិសង្វាស (សមគ្គសង្វាសតាមព្រឹត្តន័យ) ។

ក្រោយពីបានសិក្សា អំពីលក្ខណៈនៃអនីតិសង្វាស នៅក្នុងជំពូកទី១រួចមក យើងនឹងធ្វើការសិក្សាបន្ត អំពីអានុភាពអំឡុងពេលរួមអនីតិសង្វាស នៅក្នុងជំពូកទី២ជាបន្ត។

[29] ក្រមរដ្ឋប្បវេណីជប៉ុ ឆ្នាំ១៩៨០ ចាប់ពីមាត្រា ៧៣១ ដល់ មាត្រា ៧៤១

[30] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ ១៩៨០មាត្រា៧៣៩

[31] ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ ,សេចក្តីផ្តើមនីតិរដ្ឋប្បវេណី បោះពុម្ពលើកទី៧ ឆ្នាំ២០១៧ ទំព័រ១៦៨ ដល់ ទំព័រ១៦៩។ 野村豊弘『民事法入門』第 7 版（有斐閣、2017 年）168 項－169 項。

# ជំពូកទី២៖

# អានុភាពអំឡុងពេលរួមអនីតិសទ្វាស

## ជំពូកទី២៖អានុភាពអំឡុងពេលរួមអនីតិសង្វាស

ដោយសារតែអនីតិសង្វាសជាសមគ្គសង្វាសតាមព្រឹត្តន័យ ហើយវាជាទំនាក់ទំនងក្រៅគតិយុត្តរវាងបុគ្គលពីរនាក់នោះវាបង្កើតអានុភាពគតិយុត្តផ្នែកបុគ្គល និងអានុភាពផ្នែកទ្រព្យសម្បត្តិនានា។ ហេតុនេះហើយយើងនឹងសិក្សាបន្តទៀតអំពី ទំនាក់ទំនងគតិយុត្តរបស់អនីតិសង្វាសជននៅកម្ពុជា ជាផ្នែកទី១ និងទំនាក់ទំនងគតិយុត្តរបស់អនីតិសង្វាសនៅប្រទេសជប៉ុនជាផ្នែកទី២។

### ផ្នែកទី១៖ទំនាក់ទំនងគតិយុត្តដោយប្រៀបធៀបទៅនឹងច្បាប់នៅកម្ពុជា

ចំពោះទំនាក់ទំនងគតិយុត្តកម្ពុជា នៅក្នុងអំឡុងពេលរួមអនីតិសង្វាស គឺមានដូចជា៖

**១. ចំណងញាតិ**

ជាគោលការណ៍តាមផ្លូវច្បាប់ ត្រូវចាត់ទុកថាមានទំនាក់ទំនងញាតិ លុះត្រាតែសហព័ទ្ធបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយញាតិត្រូវបាន គណនាតាមថ្នាក់ញាតិមួយច្បាស់លាស់។[32] តែនៅពេលដែលមានវិវាទកើតឡើង ហើយប្ដឹងទៅតុលាការអំពីទំនាក់ទំនងញាតិ អំណាចមេបា ឬសន្តតិកម្មជាដើមនោះជាគោលការណ៍ចៅក្រមសម្រេចសេចក្ដីដោយសំអាងលើច្បាប់សារធាតុ។ ចំពោះក្នុងករណី អនីតិសង្វាស ដោយសារអវត្តមាននៃការចុះបញ្ជីអាពាហ៍ពិពាហ៍ហេតុនេះនាំឲ្យអានុភាពគតិយុត្តក្នុងការសម្រេចសេចក្ដីត្រូវបានពិចារណា ថាត្រូវទទួលស្គាល់ចំណងញាតិ ឬមិនទទួលស្គាល់ចំណងញាតិរបស់អនីតិសង្វាសជនជាឆន្ទានុសិទ្ធិរបស់ចៅក្រម។ ហេតុនេះរវាងអនីតិសង្វាសជនទាំងពីរមិនបង្កើតចំណងញាតិ និងគ្នាទេ ជាពិសេសគឺទំនាក់ទំនងជាប្ដីប្រពន្ធតាមផ្លូវច្បាប់ក៏ពុំមានដែរ។

**២. ការប្រើនាមត្រកូលប្ដីប្រពន្ធ**

នៅពេលអាពាហ៍ពិពាហ៍ស្របច្បាប់បង្កើតអានុភាពហើយ ប្ដីប្រពន្ធអាចប្រើប្រាស់នាមត្រកូលប្ដី ឬប្រពន្ធ ឬនាមត្រកូលដើម ដែលមានមុនរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន។[33] នៅប្រទេសកម្ពុជាការប្រើនាមត្រកូលគឺជាជម្រើសមិនមានលក្ខណៈដាច់ខាតនោះទេ ហើយជាទម្លាប់ និងការអនុវត្តជាក់ស្ដែង គឺប្ដីប្រពន្ធប្រើនាមត្រកូលដើមក្រោយពេលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់។ ប៉ុន្តែ អនីតិសង្វាស មិនអនុវត្តចំពោះករណីនេះឡើយ។

**៣. ការសន្មតបិតុភាព**

ទារកនៅក្នុងគភ៌ប្រពន្ធ ដែលមានក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ត្រូវសន្មតថាជាកូនរបស់ប្ដី ឬកូនដែលកើតឡើងនៅក្រោយអំឡុងពេល១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍

[32] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៣៨,៩៣៩

[33] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៦៥

ស្របច្បាប់ត្រូវបានបង្កើត ឬអំឡុងពេល៣០០ថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថាប្តីក្រោយជាឪពុករបស់កូននោះ។ [34] ករណីនេះមិនអាចអនុវត្តចំពោះអនីតិសង្វាសបានឡើយ ដោយហេតុថាគ្មានព្រឹត្តិការណ៍នៃការសន្មតតាមច្បាប់ ឬគ្មានទំនាក់ទំនងឪពុក និងកូននោះទេ ហេតុនេះកូនដែលកើតពីឪពុកម្តាយនៃទំនាក់ទំនងអនីតិសង្វាស បិតុភាព និងកើតមានឡើង លុះត្រាតែមានការទទួលស្គាល់ពីឪពុកចំពោះកូននោះ។ [35] ប៉ុន្តែឪពុកនៅតែគ្មានអំណោចមេបាដដែល មានន័យថាអ្នកមានអំណាចមេបា គឺម្តាយ[36] លើកលែងតែឪពុកដាក់ពាក្យសុំទាមទារអំណាចមេបាពីម្តាយចំពោះកូនតាមផ្លូវតុលាការ ហើយបើតុលាការសម្រេចតាម ការទាមទារនោះ នាំឲ្យអំណាចមេបាជារបស់ឪពុក។ចំពោះកូនដែលត្រូវបានទទួលស្គាស់ ឪពុកអាចក្លាយជាអ្នកដែលមានអំណាចមេបាបាន ក្រោយពេលមានការពិភាក្សារវាងឪពុក និងម្តាយ។ គួរឲ្យធ្វើការប្រុងប្រយ័ត្នថា ដោយសារតែឪពុក និងម្តាយ មិនបានរៀបអាពាហ៍ពិពាហ៍ទេ ដូច្នេះ ទោះបីជាឪពុកក្លាយជាអ្នកដែលមានអំណាចមេបាក៏ដោយ ឬ ម្តាយក្លាយជាអ្នកដែលមានអំណាចមេបាក៏ដោយក៏វាមិនមែនជាអំណាចមេបាដោយសហការគ្នាដែរ តែវានៅតែជាអំណាចមេបាទោលដដែល [37] ដោយផ្អែកមូលដ្ឋាន គឺតុលាការជាអ្នកពិចារណាលើផលប្រយោជន៍របស់កូនជាឧត្តមានុភាព ។

### ៤. អាហារកាតព្វកិច្ច

ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារនៅត្រង់មាត្រា៧៦ នៅមានសុពលភាពអនុវត្តបាន ចំពោះប្តីប្រពន្ធ ដែលបានលែងលះគ្នា ភាគីម្ខាងដែលគ្មាកំហុសហើយខ្វះខាតអាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន។ ភាគីដែលបង់ថ្លៃអាហារកិច្ចត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។ [38] ចំពោះអនីតិសង្វាសក្នុងករណីនេះមិនអនុវត្តបានឡើយ ទោះបីជាការរំលាយអនីតិសង្វាសនោះ ប្រព្រឹត្តទៅដោយគ្មានកំហុសក៏ដោយ ។

### ៥. ទ្រព្យសម្បត្តិប្តីប្រពន្ធ

ការរស់នៅបែបអនីតិសង្វាសថ្វីត្បិតតែមានសកម្មភាពដូចគ្នានឹងសហព័ទ្ធមែនប៉ុន្តែមិនអាចកើតឡើងនូវទ្រព្យសម្បត្តិណាមួយ ដែលកំណត់ដោយច្បាប់ឡើយ ដោយសារនត្ថិភាពនៃអាពាហ៍ពិពាហ៍។ ទោះជាយ៉ាងណាក្តី ការរស់នៅបែបអនីតិសង្វាសនៅក្នុងសង្គមខ្មែរយើងមានទាក់ទង នឹងការគ្រប់គ្រងទ្រព្យសម្បត្តិឃើញថាមានការអនុវត្តដោយមានការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅ

[34] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៨៨

[35] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៩៣ ដល់ ៩៩៩

[36] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ១០៣៦

[37] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៥ឆ្នាំ ២០១០

[38] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០១១

មកនៃអនីតិសង្វាស មានន័យថាបើទោះបីគ្មានសំបុត្រអាពាហ៍ពិពាហ៍ក៏អនីតិសង្វាសអាចបានគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនដោយសាមគ្គីភាព សហការគ្នាដូចសហព័ទ្ធដែរ។ ការគ្រប់គ្រងប្រកបដោយភាពរលូនគ្មានបញ្ហាអ្វីឡើយ ប្រសិនបើភាគីទាំងពីរព្រមព្រៀងគ្នាក្នុងការចាត់ចែង ឬ ក៏គ្រប់គ្រងនោះ។ ប៉ុន្តែបញ្ហាចម្បងនោះ ប្រសិនបើមិនអាចពិភាក្សាគ្នាបានទេ តើពួកគេគួរធ្វើដូចម្តេច? ដើម្បីឆ្លើយនឹងសំណួរនេះ ជាដំបូងត្រូវកំណត់ឲ្យបានច្បាស់លាស់ថាទ្រព្យសម្បត្តិណាខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់អនីតិសង្វាសជន និងទ្រព្យសម្បត្តិណាខ្លះដែលជាទ្រព្យសម្បត្តិនៃកម្មសិទ្ធិរួមនៃអ្នកទាំងពីរ ទើបអាចដោះស្រាយបញ្ហានៃការប្រើប្រាស់សិទ្ធិលើទ្រព្យសម្បត្តិទាំងនោះ។

ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិបាននៅមុនឬនៅក្រោយពេលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បាន [39] ប៉ុន្តែខចែងនេះមិនអាចបំពានសិទ្ធិទាមទារភាគបម្រុង ឬអាហារកិច្ចឡើយ។ អត្តន័យនៃប្រព័ន្ធទ្រព្យសម្បត្តិ ប្តីប្រពន្ធតាមកិច្ចសន្យា ហើយមានលក្ខណៈខុសគ្នាអំពី ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់ ហើយប្រសិនបើមិនបានចុះបញ្ជីមិនអាចតតាំងជាមួយតតិយជន។ [40] ដូច្នេះ ករណីនេះមិនអាចយកអនុវត្តចំពោះអនីតិសង្វាសឡើយ។

### ៦. ការចាត់ចែងទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ

ក្នុងទំនាក់ទំនង អនីតិសង្វាស គ្មានប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ និងប្រព័ន្ធទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាទេ។ ប៉ុន្តែអនីតិសង្វាសជន អាចធ្វើកិច្ចសន្យាកំណត់អំពីទ្រព្យសម្បត្តិដែលមានលក្ខណៈជាកិច្ចសន្យាឯកជនបាន។

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុរួមនៃអនីតិសង្វាសកើតចេញមកពី ការដាក់ទុនបើកមុខរបរជាមួយគ្នា ឬ ទិញវត្ថុណាជាមួយគ្នាជាដើម។ ក្នុងករណីនេះប្រសិនបើ មានវិវាទអំពីការប្រើប្រាស់ទ្រព្យសម្បត្តិកើតឡើងយើងត្រូវធ្វើចំណាត់ថ្នាក់ទ្រព្យសម្បត្តិទាំងនោះជាមុនសិន មានន័យថាកំណត់ទ្រព្យណាជាកម្មសិទ្ធិរួម និងទ្រព្យណាជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ការធ្វើចំណាត់ថ្នាក់សំខាន់បំផុត គឺការបង្ហាញភស្តុតាងបញ្ជាក់ឲ្យច្បាស់ថាទ្រព្យណាជារបស់ផ្ទាល់ខ្លួន និងទ្រព្យណាដែលជាកម្មសិទ្ធិរួម។

ក្នុងករណីមិនច្បាស់ពីចំណែកនៃទ្រព្យសម្បត្តិ យើងអាចកំណត់បានថា ទ្រព្យទាំងនោះជាកម្មសិទ្ធិអវិភាគហើយប្រសិនបើ មានវិវាទពីការប្រើប្រាស់ទ្រព្យ និងមិនអាចព្រមព្រៀងគ្នាទៅលើការគ្រប់គ្រង និងថែរក្សាទ្រព្យនោះទេ ជាគោលការណ៍ បញ្ញត្តិនៃកម្មសិទ្ធិអវិភាគ ត្រូវយកមកអនុវត្ត។

[39] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៦៩
[40] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៧០ កថាខណ្ឌទី២

ការចាត់ចែងទ្រព្យសម្បត្តិរួម ត្រូវតែមានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាង លើកលែងតែមានស្ថានភាពពិសេសសម្រាប់ជីវភាពរស់នៅរួម។ ប្តីប្រពន្ធណាម្ខាងអាចចាត់ចែងទ្រព្យសម្បត្តិរួមនោះបានដោយការទទួលបានការអនុញ្ញាតពីតុលាការហើយប្រសិនបើបានចាត់ចែង ដោយគ្មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត ឬគ្មានការអនុញ្ញាតពីតុលាការទេនោះ សហព័ន្ធដែលមិនបានយល់ព្រម អាចទាមទារឲ្យលុបចោលនូវការចាត់ចែងនោះបាន ដោយការដាក់ពាក្យប្តឹងទៅតុលាការនៅក្នុងអំឡុងពេល ២ឆ្នាំគិតចាប់ពីពេលដែលបានដឹង។ ក្នុងករណីនេះ ប្រសិនបើទ្រព្យដែលបានចាត់ចែងនោះជាអចលនវត្ថុ និងអំឡុងពេល ១ឆ្នាំប្រសិនបើទ្រព្យនោះមិនមែនជាអចលនវត្ថុ។ [41] ករណីនេះមិនយកមកអនុវត្តចំពោះអនីតិសង្វាសឡើយ។

### ៧. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អនីតិសង្វាសជនជាគោលការណ៍ គឺមានភាពដូចគ្នា និង ខុសគ្នាមួយចំនួន ហើយការកំណត់អំពីទ្រព្យសម្បត្តិនេះ គឺយើងអាចកំណត់បានថាទ្រព្យសម្បត្តិផ្ទាល់ខ្លួននៃអនីតិសង្វាស គឺកើតចេញសកម្មភាពគ្រប់បែបយ៉ាង នៃការកើតឡើងនៃទ្រព្យតាមរយៈការប្រកបរបររកស៊ី អាជីវកម្ម ប្រាក់ខែដែលបានមកពីការធ្វើការងារជាដើម។ លើសពីនេះ ទ្រព្យដែលបានពីការប្រទានកម្ម អច្ច័យទាន សន្តតិកម្ម ក៏ចាត់ជាទ្រព្យសម្បត្តិផ្ទាល់ខ្លួននៃអនីតិសង្វាសផងដែរ និងប្រាក់ដែលបានរកក្នុងអំឡុងពេលរស់នៅជាអនីតិសង្វាសក៏ចាត់ជាទ្រព្យផ្ទាល់ខ្លួនដូចគ្នាដែរ។ តែប្រសិនបើ គេមិនអាចធ្វើការបែងចែកបានថាទ្រព្យណាមួយជារបស់អ្នកណានោះទេ ទ្រព្យទាំងនោះគួរតែត្រូវសន្មតថាជាទ្រព្យសម្បត្តិអវិភាគ។

ចំពោះការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិផ្ទាល់ខ្លួននៃអនីតិសង្វាស គឺដូចគ្នាទៅនឹងការចាត់ចែង និងការគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធដែរ។

សហព័ទ្ធម្ខាង អាចអាស្រ័យនៅលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ដែលត្រូវបានប្រើប្រាស់អាស្រ័យនៅជាលក្ខណៈគ្រួសារ ហេតុនេះហើយបើសហព័ទ្ធដែលជាកម្មសិទ្ធករបានចាត់ចែងទ្រព្យដោយឡែករបស់ខ្លួន ក៏សហព័ទ្ធម្ខាងទៀតនៅតែមានសិទ្ធិអាស្រ័យនៅលើអចលនវត្ថុនោះ។[42] ករណីនេះមិនយកមកអនុវត្តចំពោះអនីតិសង្វាសឡើយ។

### ៨. សន្តតិកម្ម

#### ៨.១. លក្ខណៈសម្បត្តិអនីតិសង្វាសជនក្នុងការទទួលមត៌ក

[41] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៧៦

[42]ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៧៧

ដើម្បីឲ្យអនីតិសង្វាសមានសិទ្ធិលើចំណែកមតិក យើងត្រូវពិចារណាលើស្ថានភាពពីរ។ ទី១ ករណីមានមតកសាសន៍ ដែលផ្តល់ចំណែកឲ្យអនីតិសង្វាស នោះ អនីតិសង្វាសមានសិទ្ធិទទួលចំណែកក្នុងនាមជាអច្ច័យលាភី។ ទី២ ករណីគ្មានមតកសាសន៍ អនីតិសង្វាសត្រូវធ្វើការបកស្រាយទៅរកជនដែលមាននិស្ស័យពិសេស។

### ៨.២.ការទទួលបានទ្រព្យសម្បត្តិនៃសន្តតិកម្ម

#### ក. ការទទួលបានទ្រព្យសម្បត្តិតាមរយៈមតកសាសន៍

អនីតិសង្វាសជន អាចទទួលបាននូវទ្រព្យសម្បត្តិដែលជាសន្តតិកម្មរបស់អនីតិសង្វាសជនម្ខាងទៀតបានតាមរយៈមតកសាសន៍។ ក្នុងករណីនេះ ប្រសិនបើអនីតិសង្វាសជនដែលទទួលមរណភាពបានបន្សល់ទុកនូវបណ្តាំ ហើយអនីតិសង្វាសជនដែលនៅរស់ នឹងទទួលបាននូវទ្រព្យសម្បត្តិដែលកំណត់ក្នុងមតកសាសន៍នោះ។

ការធ្វើអនុប្បទានទ្រព្យសម្បត្តិតាមមតកសាសន៍ ចំពោះតតិយជន ឬ អនីតិសង្វាសជន ហៅថាអច្ច័យទាន[43] ហើយអនីតិសង្វាសជនដែលទទួលបានអច្ច័យទាននោះ ហៅថាអច្ច័យលាភី។

ការទទួលបានអច្ច័យទាននេះ អាចជាអច្ច័យទានសកល និងអច្ច័យទានកំណត់។

- **អច្ច័យទានសកល** គឺជា ប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់ ជាក់លាក់នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់តាមភាគនៃទ្រព្យ ( ទាំងអស់ ពាក់កណ្តាល, មួយភាគបី)។
- **អច្ច័យទានមានកំណត់** គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឲ្យមនុស្សម្នាក់ ឬ ច្រើននាក់ដោយមតកសាសន៍។

#### ខ. ការទទួលបានទ្រព្យសម្បត្តិតាមការកំណត់នៃច្បាប់

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ក៏បានផ្តល់សិទ្ធិឲ្យបុគ្គលមិនមែនជាញាតិអាចទទួលបានទ្រព្យសម្បត្តិខ្លះផងដែរ។ ប៉ុន្តែជននោះត្រូវគោរពលលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- ជននោះត្រូវតែមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និងជនដែលមាននិស្ស័យពិសេសផ្សេងទៀត
- នត្ថិភាពនៃសន្តតិជន

[43] អច្ច័យទាន គឺជាប្រទានកម្មដែលម្ចាស់បណ្តាំបានធ្វើទៅឲ្យមនុស្សម្នាក់ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍

- ជនដែលមាននិស្ស័យពិសេសនោះ ត្រូវដាក់ពាក្យសុំ ក្នុងអំឡុងពេល៣ ខែក្រោយអំឡុងពេលនៃការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជនបានកន្លងហួស និងត្រូវបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឲ្យច្បាស់លាស់ផងដែរ។
- មានមតិកដែលនៅសល់ក្រោយការជម្រះបញ្ជី។[44] **ឧទាហរណ៍៖** មតិកសេសសល់បន្ទាប់ពីបានធ្វើចាត់ចែងបំណុលរបស់មតិកជនហើយ។

ជនទាំងនោះ អាចជាអនីតិសង្វាស ឬ អ្នកជិតខាង ដែលមិនមែនជាញាតិនឹងគ្នា។

ប្រសិនបើ មានការទទួលស្គាល់អនីតិសង្វាស ក្នុងឋានៈជាជនដែលមាននិស្ស័យពិសេសការកំណត់ពីការផ្តល់ឲ្យនូវទ្រព្យសម្បត្តិដែលជាមតិកនោះ ក្រមរដ្ឋប្បវេណីមិនបានកំណត់ថាទទួលបានប៉ុន្មានភាគ ឲ្យបានច្បាស់ដូចសហព័ទ្ធឡើយ គ្រាន់តែបានកំណត់ថា ចំនួននៃតម្លៃទ្រព្យដែលត្រូវចែកទៅឲ្យនោះ មិនត្រូវលើសពីពាក់កណ្តាល នៃមតិកដែលនៅសេសសល់នោះទេ។[45]

សហព័ទ្ធរបស់មតកជន គឺជាសន្តតិជនជានិច្ច ហេតុនេះភាគីម្ខាងនៃអនីតិសង្វាសមិនមែនជាសន្តតិជនរបស់ភាគីម្ខាងទៀតនោះទេ។[46] ប៉ុន្តែភាគីនៃអនីតិសង្វាសអាចដាក់ពាក្យសុំទៅតុលាការដើម្បីទាមទារមរតិកមួយផ្នែក ដោយប្រើឋានៈជនមាននិស្ស័យពិសេសបាន។[47]

## ផ្នែកទី២៖ទំនាក់ទំនងគតិយុត្តដោយប្រៀបធៀបទៅនឹងច្បាប់នៅជប៉ុន

ចំពោះទំនាក់ទំនងគតិយុត្តជប៉ុន នៅក្នុងអំឡុងពេលរួមអនីតិសង្វាស គឺមានដូចជា៖

### ១. ចំណងញាតិ

ត្រូវចាត់ទុកថាមានទំនាក់ទំនងញាតិ លុះត្រាតែសហព័ទ្ធបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយញាតិត្រូវបាន គណនាតាមថ្នាក់ញាតិមួយច្បាស់លាស់។[48] ដូចនេះ បើតាមការបកស្រាយបែបផ្ទុយ អនីតិសង្វាសមិនបង្កើតទំនាក់ទំនងជាញាតិនោះទេ។ ហេតុដូចនេះ រវាងអនីតិសង្វាសជនទាំងពីរមិនបង្កើតចំណងញាតិ និងគ្នាទេ ជាពិសេសគឺទំនាក់ទំនងជាប្តីប្រពន្ធតាមផ្លូវច្បាប់ក៏ពុំមានដែរ។

### ២. ការប្រើនាមត្រកូលប្តីប្រពន្ធ

នៅប្រទេសជប៉ុន អាពាហ៍ពិពាហ៍ស្របច្បាប់បង្កើតអានុភាពហើយ ប្រពន្ធមានជម្រើសប្រើត្រកូលរបស់ប្តី ឬត្រកូលរបស់ប្រពន្ធ ប៉ុន្តែមិនអាចប្រើប្រាស់ឈ្មោះដើម ដែលមានមុនរៀប

[44] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា១២៩៦,១២៩៧ និង ១២៩៨

[45] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២០៧/០៣០,០៨ធ្នូ ២០០៧,មាត្រា១២៩៩វាក្យខណ្ឌទី១

[46] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ១១៦១

[47] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ១២៩៩

[48] មាត្រា ៧២៥ នៃក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ ១៩៨០

អាពាហ៍ពិពាហ៍ស្របច្បាប់នោះបានទេ។ ជារួមស្ត្រីជាជនជាតិជប៉ុនត្រូវផ្លាស់ប្តូរឈ្មោះរបស់ខ្លួន ហើយប្រើប្រាស់ត្រកូលរបស់ខ្លួន ឬត្រកូលរបស់ប្តី ក្រោយរៀបអាពាហ៍ពិពាហ៍។[49] ប៉ុន្តែ អនីតិសង្វាស មិនអនុវត្តចំពោះករណីនេះឡើយ។

**៣. ការសន្មតបិតុភាព**

ទារកនៅក្នុងគភ៌ប្រពន្ធ ដែលមានក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ត្រូវសន្មតថាជាកូនរបស់ប្តី ឬកូនដែលកើតឡើងនៅក្រោយអំឡុងពេល២០០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ស្របច្បាប់ត្រូវបានបង្កើត ឬអំឡុងពេល៣០០ថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថាប្តីក្រោយជាឪពុករបស់កូននោះ។[50] ករណីនេះមិនអាចអនុវត្តចំពោះអនីតិសង្វាសបានឡើយ ដោយហេតុថាគ្មានព្រឹត្តិការណ៍នៃការសន្មតតាមច្បាប់ ឬគ្មានទំនាក់ទំនងឪពុក និងកូននោះទេ ហេតុនេះកូនដែលកើតពីឪពុកម្តាយនៃទំនាក់ទំនងអនីតិសង្វាស គឺជាកូនឥតខាន់ស្លា ដូចនេះបិតុភាព និងកើតមានឡើង លុះត្រាតែមានការទទួលស្គាល់ពីឪពុកចំពោះកូននោះ។[51]

**៤. អាហារកាតព្វកិច្ច**

នៅប្រទេសជប៉ុន ពុំមានច្បាប់ណាមួយ ដែលចែងឲ្យបានច្បាស់លាស់ទាក់ទងនឹងអាហារកាតព្វកិច្ចឡើយ។ ប៉ុន្តែ តាមរយៈមាត្រា ៧៦៨ នៃក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ ស្តីពីការលែងលះ គឺប្តីប្រពន្ធ ដែលបានលែងលះគ្នា ហើយភាគីម្ខាងមានកំហុសភាគីម្ខាងនោះត្រូវទទួលខុសត្រូវចំពោះអាហារកាតព្វកិច្ចក្រោយលែងលះ ប្រសិនបើមានការស្នើសុំពីភាគីម្ខាងទៀត។ ចំពោះអនីតិសង្វាសក្នុងករណីនេះមិនអនុវត្តបានឡើយ ទោះបីជាការរំលាយអនីតិសង្វាសនោះ ភាគីម្ខាងទៀតមានកំហុសក៏ដោយ ។

**៥. ទ្រព្យសម្បត្តិ ប្តីប្រពន្ធ**

នៅប្រទេសជប៉ុនប្តីប្រពន្ធអាចធ្វើកិច្ចសន្យាទ្រព្យសម្បត្តិបាននៅមុនការចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់បាន។ ប៉ុន្តែ អត្ថន័យនៃប្រព័ន្ធទ្រព្យសម្បត្តិ ប្តីប្រពន្ធតាមកិច្ចសន្យា មានលក្ខណៈខុសគ្នាអំពី ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធតាមច្បាប់ ត្រង់ចំណុចថា មុនពេលមានការចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ ប្រសិនបើប្រព័ន្ធទ្រព្យសម្បត្តិ ប្តីប្រពន្ធតាមកិច្ចសន្យា មិនបានចុះបញ្ជីទេ

[49] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ ១៩៨០ មាត្រា ៧៥០
[50] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ ១៩៨០ មាត្រា ៧៧២
[51] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៧៧៩ ដល់ ៧៨២

គឺមិនអាចតតាំងជាមួយអ្នកបន្តវេន និងតតិយជនបានឡើយ។[52] ដូច្នេះ ករណីនេះមិនអាចយកអនុវត្តចំពោះអនីតិសង្វាសឡើយ។

**៦. ការចាត់ចែងទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ និងទ្រព្យសម្បត្តិដោយឡែក**

នៅប្រទេសជប៉ុន មិនធ្លាប់មានទំនៀមទំលាប់នៃការចាត់ចែង នូវប្រព័ន្ធទ្រព្យសម្បត្តិរួម និងដោយឡែករបស់ប្តីប្រពន្ធទេ ហើយក៏មិនមានការកំណត់នូវប្រភេទនៃប្រព័ន្ធទ្រព្យសម្បត្តិបែបនោះជាពិសេសអ្វីដែរ ដោយសារតែប្រព័ន្ធទ្រព្យសម្បត្តិត្រូវកំណត់ទៅតាមការព្រមព្រៀងគ្នាដោយសេរីរបស់ប្តីប្រពន្ធ [53] ហើយក្នុងករណីដែលគ្មានការព្រមព្រៀងគ្នាទេ ប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ដែលមានតែ ៣ មាត្រា ត្រូវយកមកអនុវត្ត។[54] ករណីនេះមិនយកមកអនុវត្តចំពោះអនីតិសង្វាសឡើយ។

**៧. សន្តតិកម្ម**

នៅប្រទេសជប៉ុនសហព័ទ្ធរបស់មតកជន គឺជាសន្តតិជនជានិច្ច ហេតុនេះភាគីម្ខាងនៃអនីតិសង្វាសមិនមែនជាសន្តតិជនរបស់ភាគីម្ខាងទៀតនោះទេ។[55] ប៉ុន្តែភាគីនៃអនីតិសង្វាសអាចដាក់ពាក្យសុំទៅតុលាការដើម្បីទាមទារមរតកមួយផ្នែក ដោយប្រើឋានៈជនមាននិស្ស័យពិសេសបាន។[56]

ក្រោយពីបានសិក្សាអំពីអំពីអានុភាពអំឡុងពេលរួមអនីតិសង្វាស ក្នុងជំពូកទី២រួចមក យើងនឹងធ្វើការសិក្សាបន្ត អំពីការរំលាយនៃអនីតិសង្វាស នៅក្នុងជំពូកទី៣។

[52] ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ មាត្រា ៧៥៥, ៧៥៦

[53] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៧៥៥

[54] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៧៥៥ ដល់ ៧៥៩

[55] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៨៩០

[56] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៥៨

# ជំពូកទី៣៖

# ការរំលាយនៃអនីតិសង្វាស

# ជំពូកទី៣៖ ការរំលាយនៃអនីតិសង្វាស

ថ្វីត្បិតតែអនីតិសង្វាសជាចំណងក្រៅគតិយុត្តក៏ពិតមែន ប៉ុន្តែវាក៏មាននីតិវិធីនៃការរំលាយចំណងអនីតិសង្វាសនេះមិនខុសពីអាពាហ៍ពិពាហ៍ស្របច្បាប់ប៉ុន្មានទេ។ ដោយសារក្រោយពីបង្កើតចំណងអនីតិសង្វាសហើយ បានបង្កជាចំណងនានាដែលធ្វើឲ្យមានបញ្ហាដល់ភាគីទាំងសងខាងរបស់អនីតិសង្វាសជនទាំងពីរ។ ហេតុនេះយើង នឹងធ្វើការសិក្សាបន្តទៅទៀតអំពី សញ្ញាណនៃការរំលាយអនីតិសង្វាសនៅផ្នែកទី១ និងអានុភាពនៃការរំលាយអនីតិសង្វាសនៅផ្នែកទី២។

## ផ្នែកទី១៖ សញ្ញាណនៃការរំលាយអនីតិសង្វាស

### ១. មូលហេតុនៃការរំលាយអនីតិសង្វាសនៅកម្ពុជា និង ជប៉ុន

អាពាហ៍ពិពាហ៍ មិនអាចត្រូវបានរំលាយដោយសេរី ដោយការបង្ហាញឆន្ទៈរបស់ភាគីនោះទេ គឺត្រូវមានការអនុញ្ញាត ឬសេចក្តីសម្រេចរបស់តុលាការ ដូច្នេះដើម្បីអាចលែងលះបាន លុះត្រាតែមានមូលហេតុណាមួយក្នុងចំណោមមូលហេតុនានា ដែលច្បាប់កំណត់ដូចជា **ទី១** ផិត **ទី២** បោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ **ទី៣** មិនដឹងថាសហព័ទ្ធស្លាប់ ឬ រស់រយៈពេលជាង ១ ឆ្នាំ **ទី៤** សហព័ទ្ធបានរស់នៅបែកគ្នា ជាបន្តបន្ទាប់អស់រយៈពេលជាង១ឆ្នាំ ផ្ទុយទៅនិងគោលបំណងនៃអាពាហ៍ពិពាហ៍ បែកបាក់ និងគ្មានសង្ឃឹមថាអាចធ្វើឲ្យបានដូចដើមវិញបាន។

ដោយឡែកចំពោះករណីអនីតិសង្វាសមានចំណុចមួយចំនួនមានការលំបាក ក្នុងការបែងចែកថា៖ តើគួរតែអនុវត្តអនីតិសង្វាស ប្រដូច និងនីតិសង្វាស ឬយ៉ាងណានៅក្នុងករណីខាងក្រោមនេះ ដូចជា៖

ចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ តុលាការដែលបានទទួលពាក្យបណ្តឹងលែងលះ ក្នុងករណីចាំបាច់តុលាការអាចចេញដីការសម្រេចចាត់ចែងរក្សាការពារដូចជា៖

ទី១ ការបំបែកលំនៅសង្វាស

ទី២ ការគ្រប់គ្រងថែរក្សាកូន

ទី៣ ការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ

ទី៤ អាហារកិច្ចរវាងសហព័ទ្ធ

ទី៥ សោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍ ។

ការចេញដីកាសម្រេចនេះ គឺធ្វើឡើងបានតាមការដាក់ពាក្យសុំរបស់ភាគីទៅតុលាការ ឬតាមឆន្ទានុសិទ្ធិរបស់តុលាការ។ ដូចនេះចំពោះ ករណីអនីតិសង្វាសមិនទាន់បានកំណត់នៅឡើយថា តើគួរយកមកអនុវត្ត ប្រដូច និងនីតិសង្វាស ឬ យ៉ាងណា។

ដោយឡែកអនីតិសង្វាសអាចត្រូវបានបញ្ចប់ក្នុងករណីដូចតទៅ៖

១. ការចុះបញ្ជីអាពាហ៍ពិពាហ៍

២. ការប្រកាសបាត់ខ្លួន

៣. មរណភាព

៤. ការឈប់រស់នៅជាមួយគ្នា។

## ២. នីតិវិធីនៃការរំលាយអនីតិសង្វាសនៅកម្ពុជា

### ២.១. បណ្តឹង

នៅក្នុងរឿងក្តីអនីតិសង្វាសជាញឹកញាប់ គឺដើមចោទតែងតែប្តឹងទាមទារ សុំបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍ពីចុងចម្លើយ។

ចាប់ពី ឆ្នាំ២០១៣ មកមានការផ្លាស់ប្តូរ កម្មវត្ថុនៃបណ្តឹងពី បណ្តឹងទាមទារសុំផ្តាច់សមគ្គសង្វាសទៅជា បណ្តឹងសុំបញ្ជាក់នត្ថិភាព នៃអាពាហ៍ពិពាហ៍។

ជាក់ស្តែងយោងទៅតាមសាលក្រមសាលាដំបូងរាជធានីភ្នំពេញ គឺដើមចោទប្តឹងទាមទារ ឈប់រស់នៅជាអនីតិសង្វាស សុំសិទ្ធិអំណាចមេបាលើកូន និងសុំទាមទារគ្រប់គ្រងកាន់កាប់ទ្រព្យសម្បត្តិ។[57]

#### ក. ការដាក់ពាក្យបណ្តឹងទៅតុលាការ

- ពាក្យបណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ
- ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងមាន៖

  ១. ឈ្មោះ ឬនាមករណ៍ និងអាស័យដ្ឋានរបស់ភាគី និង អ្នកតំណាងដែលច្បាប់បានកំណត់ ។

  ២.ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ។

  ៣.គប្បីសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ នូវអង្គហេតុដែលមូលហេតុនៃការទាមទារ និង អង្គហេតុសំខាន់ៗ ដែលត្រូវបញ្ជាក់ដោយភស្តុតាង។[58]
- ដើមចោទត្រូវបង់ពន្ធដាក់ពាក្យសុំប៉ុន្តែលើកលែងតែករណីការផ្តល់ជំនួយសង្គ្រោះលើបណ្តឹង។[59]

---

[57] សំណុំរឿងរដ្ឋប្បវេណីលេខ ២៦៩២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨,ពាក្យបណ្តឹង ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩នៃសាលាដំបូងរាជធានីភ្នំពេញ

[58] ក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦, មាត្រា ៧៥

[59]ក្រមនីតិវិធីរដ្ឋប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦,មាត្រា ៦៩

- ការបែងចែករឿងក្តី។[60]

ក្រឡាបញ្ជី ដែលបានចុះលេខរឿងក្តី ត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមដែលត្រូវទទួលបន្ទុកតាមលំដាប់ ដែលបានកំណត់ ។

**ខ. ការពិនិត្យពាក្យបណ្តឹង**

តុលាការ ធ្វើការពិនិត្យពាក្យបណ្តឹង[61] ដោយយោង លើមាត្រាដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដូចជា៖

ក្នុងករណីដែលពាក្យបណ្តឹងមានចំណុចខ្វះខាត (របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងបណ្តឹង) តុលាការកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាត។ ម្យ៉ាងទៀត តុលាការលើកបណ្តឹងចោលដោយដីកាសម្រេច បើមិនកែតម្រូវ ហើយតុលាការ លើកបណ្តឹងចោលដោយសាលក្រម បើបណ្តឹងនោះផ្ទុយនឹងច្បាប់។[62]។

ការពិនិត្យពាក្យបណ្តឹង នៃក្រមរដ្ឋប្បវេណី ដែលបានកំណត់អំពីលក្ខខណ្ឌ នៃពាក្យបណ្តឹងដោយចាត់ទុកពន្ធដាក់ពាក្យសុំ ក៏ជាលក្ខខណ្ឌសុពលភាព នៃបណ្តឹងដែរ។[63] ជាក់ស្តែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់អំពីការគណនាពន្ធដាក់ពាក្យសុំ ទៅតាមតំលៃនៃកម្មវត្ថុនៃបណ្តឹង [64] ចំពោះចំណាងអាពាហ៍ពិពាហ៍ស្របច្បាប់។ ប៉ុន្តែ ពន្ធលើពាក្យសុំចំពោះរឿងអនីតិសង្វាសវិញ តុលាការត្រូវតែ កំណត់តំលៃ ដោយឆន្ទានុសិទ្ធិសមហេតុផល។ ក្នុងករណីដែលតំលៃនោះ មិនអាចគណនាបានទេ នោះត្រូវចាត់ទុកថា មានចំនួន ៥.៥០០.០០០០រៀល។[65]

**២.២. ដំណើរការនៃនីតិវិធី**

បន្ទាប់ពីទទួលបានពាក្យសុំ ឬពាក្យបណ្តឹងនៃការបញ្ចប់អនីតិសង្វាស សាលាជម្រះក្តី នឹងដំណើរការនីតិវិធីរឿងក្តីនេះ ដោយឈរលើច្បាប់ស្តីពី នីតិវិធីបណ្តឹងស្តីពីឋានៈបុគ្គល ដោយធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុ រួចចេញដីការសម្រេច ក្នុងករណីមានការផ្សះផ្សារគ្នារវាងគូភាគី ឬដោយឈរលើក្រមនីតិវិធីរដ្ឋប្បវេណីដែលជាបញ្ញត្តិទូទៅ៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ឬក៏លើកពាក្យបណ្តឹងចោល។ នៅជំណាក់កាលនីតិវិធីត្រៀម

[60] ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦,មាត្រា ២៦
[61] ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦,មាត្រា ៧៨
[62]ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦, មាត្រា ៨១
[63]ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦, មាត្រា ៧៨ កថាខណ្ឌទី១ វាក្យខណ្ឌទី១
[64]ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦,មាត្រា៦១
[65] ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦,មាត្រា៦០ កថាខណ្ឌទី៣

ជាទូទៅគូភាគីតែងតែ ធ្វើសេចក្តីថ្លែងការណ៍អំពីមូលហេតុដែលទាមទារនាំឲ្យមាន ការបញ្ជាក់ពីនត្ថិភាព នៃអាពាហ៍ពិពាហ៍ ពីចុងចម្លើយ។

តើការថែរក្សាការពារអាចយកមកអនុវត្តនៅក្នុងរឿងក្តីអនីសង្វាសបានដែរឬទេ? បើបាន តើបានក្នុងទំហំណា? ករណីដែលទទួលបណ្តឹង លែងលះគ្នា (អាពាហ៍ពិពាហ៍ស្របច្បាប់) ក្នុងករណីចាំបាច់អាចចេញដីការសម្រេចបង្គាប់ ឲ្យធ្វើការចាត់ចែងរក្សាការពារដូចជា ៖ ការបំបែកលំនៅសង្វាស ការគ្រប់គ្រងថែរក្សាកូន ការគ្រប់គ្រងរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធបន្ទុកនៃសោហ៊ុយ នៃអាពាហ៍ពិពាហ៍ និងសោហ៊ុយចញ្ចឹមបីបាច់កូន ជាអាទិ៍ តាមពាក្យសុំ ឬតាមឆន្ទានុសិទ្ធិរបស់តុលាការ ។ ដូចនេះ ក្នុងការចាត់ចែងរក្សាការពារក្នុងរឿង អនីតិសង្វាស តើគួរតែអាចអនុវត្តបានដោយយោងលើករណីខាងលើ ឬទេ?

**២.៣. ការវិនិច្ឆ័យសេចក្តី**

ក្នុងការអនុវត្តជាក់ស្តែង នៅសាលាជំនុំជម្រះក្តី តុលាការបានខ្ចីបញ្ញត្តិ ស្តីពីអាពាហ៍ពិពាហ៍នៅក្នុងក្រមរដ្ឋប្បវេណីទៅអនុវត្តនៅក្នុងរឿងក្តីអនីតិសង្វាស ដោយតុលាការលើកបណ្តឹងពីការផ្តាច់សមគ្គសង្វាសចំពោះអនីតិសង្វាសចោលពីចុងចម្លើយ ដោយយល់ថាពាក្យបណ្តឹងផ្ទុយនិងច្បាប់ [66] (តុលាការអាចទទួលយក បណ្តឹងទាមទារបញ្ជាក់នត្ថិភាពនៃអាពាហ៍ពិពាហ៍)។ ការច្រានចោលបណ្តឹងបែបនេះតុលាការមិនបានបង្ហាញអំពីទឡ្ហីករណ៍គតិយុត្តណាមួយច្បាស់លាស់នោះទេ ដោយគ្រាន់តែសំអាងថា វាជាបណ្តឹងដែលផ្ទុយនឹងច្បាប់តែប៉ុណ្ណោះ។ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងនារីម្នាក់ដែល ប្តេជ្ញាថាខ្លួន នឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញាត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ ។ រីឯ អនីតិសង្វាសវិញ មិនមានចែងនៅក្នុងច្បាប់ណាមួយនោះទេ តែមានតែក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ២២២ តែប៉ុណ្ណោះ ដែលបានលើកឡើងអំពីសញ្ញាណនេះ តែមិនបានកំណត់ពីលក្ខណៈច្បាស់លាស់នោះទេ។ ដូច្នេះការច្រានចោលបណ្តឹង របស់ដើមចោទ ដែលប្តឹងសុំទាមទារផ្តាច់សមគ្គសង្វាស ពីចុងចម្លើយ នឹងហាក់ដូចជាមិនបានផ្តល់ទឡ្ហីករណ៍ច្បាស់លាស់នៅឡើយ ។ អាស្រ័យហេតុនេះហើយចាំបាច់ទាមទារឲ្យមានការសរសេរកម្មវត្ថុនៃបណ្តឹង និង ការប្រើពាក្យនៅក្នុងសេចក្តីសម្រេចរបស់តុលាការ ឲ្យបានត្រឹមត្រូវ ។ ជាក់ស្តែង បើមានចំណងអាពាហ៍ពិពាហ៍ត្រូវប្រើពាក្យ សុំលែងលះគ្នា តែបើគ្មានចំណងអាពាហ៍ពិពាហ៍ទេ(អនីតិសង្វាស) ត្រូវប្រើពាក្យ សុំទាមទារបញ្ជាក់នត្ថិភាព នៃអាពាហ៍ពិពាហ៍ជាដើម ជៀសវាងការប្រើពាក្យ សុំផ្តាច់សមគ្គសង្វាស។[67]

---

[66] ក្រមនីតិវិធីរប្បវេណីប្រទេសកម្ពុជាលេខ,នស/រកម/០៧០៦/០២១,០៦កក្កដា ២០០៦,មាត្រា៨១

[67] ចក សម្បត្តិ(អនីតិសង្វាស) ឆ្នាំ២០១៤ ទំព័រទី២០

**២.៤. ការអនុវត្តជាក់ស្តែងចំពោះអនីតិសង្វាស**

ការអនុវត្តរបស់អនីតិសង្វាសមិនទាន់មានលក្ខណៈឯកភាព និងគោលការណ៍ច្បាស់លាស់ក្នុងការបកស្រាយនៅឡើយនោះទេ ដោយហេតុថាការអនុវត្តជាក់ស្តែងមានសាលក្រម ដែលត្រូវបានចេញឲ្យរំលាយអនីតិសង្វាស និងសាលក្រមលើកចោលបណ្តឹងទាមទារឲ្យរំលាយអនីតិសង្វាស មានន័យថាតុលាការខ្លះទទួលស្គាល់ តុលាការខ្លះមិនទទួលស្គាល់។

នៅក្នុងនីតិវិធីនៃការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ គេអាចធ្វើបានតាមរយៈការដាក់ពាក្យសុំប្រសិនបើប្តី ប្រពន្ធនោះព្រមព្រៀងគ្នាលែងលះ[68] ដោយប្រើនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ ផ្ទុយទៅវិញ ប្រសិនបើប្តី ប្រពន្ធនោះមិនព្រមព្រៀងគ្នាលែងលះនោះទេ ភាគីដែលមានបំណងត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ [69] ដោយប្រើប្រាស់នីតិវិធីបណ្តឹងឋានៈបុគ្គល និងមានមូលហេតុស្របច្បាប់។[70]

**៣. នីតិវិធីនៃការរំលាយអនីតិសង្វាសនៅជប៉ុន**

**៣.១. បណ្តឹង**

ភាគច្រើនបណ្តឹងនៅប្រទេសជប៉ុន គឺដើមចោទប្តឹងទាមទារ ឈប់រស់នៅជាអនីតិសង្វាស សុំសិទ្ធិអំណាចមេបាលើកូន និងសុំទាមទារគ្រប់គ្រង កាន់កាប់ទ្រព្យសម្បត្តិ។ [71]

**ក. ការដាក់ពាក្យបណ្តឹងទៅតុលាការ**

- ការប្តឹងត្រូវធ្វើដោយដាក់ពាក្យបណ្តឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ទៅតុលា ការ ។
- នៅក្នុងលិខិតនៃពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោម៖

  ១. ឈ្មោះ ឬនាមករណ៍ និងអាស័យដ្ឋានរបស់ភាគី ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់ អ្នកតំណាងដែលច្បាប់បានកំណត់ ។

  ២. ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ ។[72]

---

[68] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៧៩

[69] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៨២

[70] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៩៧៨

[71] អ៊ឺឈីដា គីធុ ,នីតិរដ្ឋប្បវេណីភាគទី៤ ស្តីពីញាតិនិងសន្តតិកម្ម បោះពុម្ពលើកទី៦ ឆ្នាំ២០០៤ ទំព័រ១៤១ដល់១៥០។ 内田貴著『民法 4 親族・相続』第 6 版（有斐閣、2004 年）141 から 150 項。

[72]ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៩៦ មាត្រា ១៣៣

- ដើមចោទត្រូវបង់ពន្ធដាក់ពាក្យសុំប៉ុន្តែលើកលែងតែករណីការផ្តល់ជំនួយសង្រ្គោះលើបណ្តឹង។[73]

**ខ. ការពិនិត្យពាក្យបណ្តឹង**

តុលាការ ធ្វើការពិនិត្យពាក្យបណ្តឹង[74] ដោយយោង លើមាត្រាដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដូចជា៖

ក្នុងករណីដែលពាក្យបណ្តឹងមានចំណុចខ្វះខាត (របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងបណ្តឹង) តុលាការកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាត។ ម្យ៉ាងទៀត តុលាការលើកបណ្តឹងចោលដោយដីកាសម្រេច បើមិនកែតម្រូវហើយតុលាការ លើកបណ្តឹងចោលដោយសាលក្រម បើបណ្តឹងនោះផ្ទុយនឹងច្បាប់។[75]

ការពិនិត្យពាក្យបណ្តឹង នៃក្រមរដ្ឋប្បវេណី ដែលបានកំណត់អំពីលក្ខខណ្ឌ នៃពាក្យបណ្តឹងដោយចាត់ទុកពន្ធដាក់ពាក្យសុំ ក៏ជាលក្ខខណ្ឌសុពលភាព នៃបណ្តឹងដែរ។[76] ជាក់ស្តែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនមិនបានកំណត់ អំពីការគណនាពន្ធដាក់ពាក្យសុំ ទៅតាមតំលៃនៃកម្មវត្ថុនៃបណ្តឹងចំពោះអាពាហ៍ពិពាហ៍ស្របច្បាប់ ដូចកម្ពុជាឡើយ។ ប៉ុន្តែ ពន្ធលើពាក្យសុំចំពោះរឿងអនីតិសង្វាសវិញ តុលាការត្រូវតែ កំណត់តំលៃ ដោយឆន្ទានុសិទ្ធិសមហេតុផល។

**៣.២. ដំណើរការនៃនីតិវិធី**

នៅប្រទេសជប៉ុន បន្ទាប់ពីទទួលបានពាក្យសុំ ឬពាក្យបណ្តឹងនៃការបញ្ចប់អនីតិសង្វាសសាលាជម្រះក្តី នឹងដំណើរការនីតិវិធីរឿងក្តីនេះ ដោយឈរលើច្បាប់ស្តីពី នីតិវិធីបណ្តឹងស្តីពីឋានៈបុគ្គល ដោយធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រួចចេញដីកាសម្រេច ក្នុងករណីមានការផ្សះផ្សារគ្នារវាងគូភាគី ឬ ដោយឈរលើក្រមនីតិវិធីរដ្ឋប្បវេណីដែលជាបញ្ញត្តិទូទៅ៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ឬក៏លើកពាក្យបណ្តឹងចោល ។ នៅដំណាក់កាលនីតិវិធីត្រៀម ជាទូទៅគូភាគីតែងតែ ធ្វើសេចក្តីថ្លែងការណ៍អំពីមូលហេតុដែលទាមទារនាំឲ្យមាន ការបញ្ជាក់ពីនត្ថិភាព នៃអាពាហ៍ពិពាហ៍ ពីចុងចម្លើយ។

**៣.៣. ការវិនិច្ឆ័យសេចក្តី**

[73] ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៩៦ មាត្រា ៨២

[74] ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៩៦ មាត្រា ១៣៧

[75] ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនមាត្រាឆ្នាំ១៩៩៦ មាត្រា១៤០, ៧៨

[76] ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៩៦ មាត្រា ១៣៧ កថាខណ្ឌទី១ វាក្យខណ្ឌទី១

ករណីជប៉ុន ដោយសារតែអនីតិសង្វាស មិនមានចែងនៅក្នុងច្បាប់ជប៉ុនណាមួយនោះទេ ដូច្នេះ ការអនុវត្តជាក់ស្តែង នៅសាលាជំនុំជម្រះក្តី តុលាការបានខ្ចីបញ្ញត្តិ ស្តីពីអាពាហ៍ពិពាហ៍នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនទៅអនុវត្តនៅក្នុងរឿងក្តីអនីតិសង្វាស។ បន្ថែមពីនេះទៅទៀត ការច្រានចោលបណ្តឹង របស់ដើមចោទ ដែលប្តឹងសុំទាមទារផ្តាច់សមគ្គសង្វាស ពីចុងចម្លើយ ហាក់ដូចជាមិនបានផ្តល់ទឡ្ហីករណ៍ច្បាស់លាស់នៅឡើយ។ អាស្រ័យហេតុនេះហើយ ចាំបាច់ទាមទារអោយមានការសរសេរកម្មវត្ថុនៃបណ្តឹង និង ការប្រើពាក្យនៅក្នុងសេចក្តីសម្រេចរបស់តុលាការ អោយបានត្រឹមត្រូវ ។

### ៣.៤. ការអនុវត្តជាក់ស្តែងចំពោះអនីតិសង្វាស

នៅប្រទេសជប៉ុន ដោយសារតែអនីតិសង្វាស មិនមានចែងនៅក្នុងច្បាប់ជប៉ុនណាមួយនោះទេ ដូច្នេះ ការអនុវត្តរបស់អនីតិសង្វាសមិនទាន់មានលក្ខណៈឯកភាព និងមានគោលការណ៍ច្បាស់លាស់ក្នុងការបកស្រាយនៅឡើយនោះទេ។ ដោយហេតុថាការអនុវត្តជាក់ស្តែងមានសាលក្រមខ្លះ ចេញឲ្យរំលាយអនីតិសង្វាស និងសាលក្រមមួយចំនួនទៀតលើកចោលបណ្តឹងទាមទារឲ្យរំលាយអនីតិសង្វាស។ បែបនេះមានន័យថាតុលាការខ្លះទទួលស្គាល់ តុលាការខ្លះមិនទទួលស្គាល់ ។

## ផ្នែកទី២៖ អនុភាពនៃការរំលាយអនីតិសង្វាស

ការរំលាយចំណងអាពាហ៍ពិពាហ៍ស្របច្បាប់(លែងលះ) ត្រូវតែមានដីកាសម្រេច ឬសាលក្រមរបស់តុលាការ ប៉ុន្តែករណីការរំលាយអនីតិសង្វាសអាចធ្វើឡើងតាមការព្រមព្រៀមរបស់គូភាគីក៏បាន ឬតាមសេចក្តីសម្រេចរបស់តុលាការ។ ទោះបីមានពាក្យបណ្តឹង ឬ ពាក្យសុំឲ្យរំលាយអនីតិសង្វាស ឬសុំផ្តាច់អនីតិសង្វាសក៏ដោយ ពាក្យបណ្តឹងនោះនឹងត្រូវលើកចោលដោយសាលក្រមដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[77] ដោយហេតុថា បណ្តឹងនោះជាបណ្តឹងផ្ទុយច្បាប់ហើយចំណុចដែលខ្វះខាតរបស់ពាក្យបណ្តឹងនេះមិនអាចកែតម្រូវបានឡើយ។ ប៉ុន្តែ តុលាការអាចទទួលយកពាក្យបណ្តឹង ទាមទារសុំឲ្យបញ្ជាក់នត្ថិភាព នៃអាពាហ៍ពិពាហ៍ ពីអនីតិសង្វាសជនបាន។

ប្រសិនបើភាគីនៃអនីតិសង្វាសមានឆន្ទៈរំលាយអនីតិសង្វាស ភាគីនោះអាចធ្វើឡើងតាមការព្រមព្រៀងគ្នា ដោយហេតុថា អនីតិសង្វាសគឺកើតឡើងតាមព្រឹត្តន័យ ឬសេរីហើយលក្ខណៈជាក់ស្តែងមិនមែនជាចំណងគតិយុត្ត ព្រមទាំងនៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់វិជ្ជមាននានានៅកម្ពុជា គ្មានបញ្ញត្តិគ្រប់គ្រងទៅលើបញ្ហាអនីតិសង្វាសនោះទេ ហេតុនេះការទាមទារផ្តាច់សមគ្គសង្វាសមិនអាចសម្រេចបានតាមផ្លូវតុលាការនោះទេ ពីព្រោះតុលាការសម្រេចសេចក្តីដោយផ្អែកលើភស្តុ

[77]ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៩៦ មាត្រា១៤០

តាង និង បញ្ញត្តិច្បាប់មិនមែនផ្អែកលើការយល់ ឃើញ ឬ ឆន្ទានុសិទ្ធិក្រៅវង្វង់ច្បាប់ ឬហួសវិសាលភាពច្បាប់នោះទេ។

## ១. ករណីនៅកម្ពុជា

### ១.១. អំណាចមេបាចំពោះកូន

ឪពុកម្តាយ ដែលមានចំណងអាពាហ៍ពិពាហ៍ស្របតាមច្បាប់ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការ ប៉ុន្តែចំពោះកូនដែលកើតឡើងក្នុងទំនាក់ទំនងអនីតិសង្វាស គឺមានតែអំណាចមេបាទោល ដែលជាម្តាយប៉ុណ្ណោះ ។ ហេតុដែលបណ្តាលឲ្យមានតែម្តាយពីព្រោះស្ត្រីជាអ្នកសម្រាលកូន គឺជាម្តាយរបស់កូននោះ[78] ចំណែកឪពុកវិញ គឺគ្មានមូលហេតុបិតុភាពតាមច្បាប់នោះទេ លើកលែងតែឪពុកបានទទួលស្គាល់កូននោះដោយស្ម័គ្រចិត្ត និងបានចុះសំបុត្រកំណើតកូនដោយដាក់ឈ្មោះខ្លួនថាជាឪពុករបស់កូននោះ វាជាហេតុនាំឲ្យមានទំនាក់ទំនងជាឪពុក និងកូនកើតឡើង។[79]

ឪពុកម្តាយនៃចំណងអាពាហ៍ពិពាហ៍ ដែលពុំមានអំណាចមេបា ក្រោយការលែងលះមានសិទ្ធិប្រាស្រ័យជួបទាក់ទងជាមួយនឹងកូនបាន និងត្រូវទទួលបន្ទុកនូវសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន។[80] ដោយឡែកអនីតិសង្វាស ស្ត្រីដែលជាម្តាយមិនអាចទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនពីឪពុកបាននោះទេ លើកលែងតែឪពុកនោះបានទទួលស្គាល់កូន។ ប្រសិនបើឪពុកទទួលស្គាល់កូន អាចពិភាក្សា និងកំណត់ជាមួយម្តាយអំពីរបៀបចូលប្រាស្រ័យទាក់ទងគ្នា និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុដើម្បីគ្រប់គ្រងថែរក្សាកូន។[81]

### ១.២.សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន

ក្នុងករណីដែលមានការទទួលស្គាល់ទំនាក់ទំនងឪពុក និងកូនបានកើតឡើងនោះឪពុក ឬម្តាយណាដែលមិនមានអំណាចមេបាចំពោះកូនអាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបានដូចក្នុងករណីអាពាហ៍ពិពាហ៍ដែរ ព្រមទាំងមានកាតព្វកិច្ចទទួលខុសត្រូវលើបន្ទុកសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន។ ការកំណត់អំពីការចូលជួប និងប្រស្រ័យទាក់ទងជាមួយកូន និង

---

[78]ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ , មាត្រា៩៨៧

[79]ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ , មាត្រា ៩៩៣ ដល់ ៩៩៩

[80]ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ , មាត្រា ១០៤០

[81] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ ,មាត្រា ១០៤០ កថាខ័ណ្ឌទី៣

សោហ៊ុយ ចាំបាច់សម្រាប់ការគ្រប់គ្រងចិញ្ចឹមថែរក្សាកូនធ្វើឡើងដោយឆន្ទៈសេរីរបស់ភាគី លើកលែងតែមានការពិភាក្សាគ្នាមិនត្រូវគ្នា ។

ការលើកឡើងខាងលើបែបនេះគឺស្របទៅ នឹងកថាខ័ណ្ឌទី៣ មាត្រា១០៤០ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧បានចែងថា ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និងកំណត់ជាមួយម្ដាយ អំពីរបៀបជួបប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងរក្សាកូនបាន។ ប្រសិនបើស្ថិតក្នុងករណីពុំបានសម្រេច ឬ ប្រសិនបើពុំអាចធ្វើការពិភាក្សាគ្នាបានទេ ត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការ ហើយវាគឺជាការចាំបាច់បំផុតក្នុងការកំណត់ និងផ្លាស់ប្ដូរដែលត្រូវទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយតុលាការយកប្រយោជន៍របស់កូនជាអាទិភាព និងដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ឪពុក ឬម្ដាយនោះ ។

**១.៣.ការទាមទារផ្នែកទ្រព្យសម្បត្តិ**

អនីតិសង្វាសពុំមានប្រព័ន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធរួម និងប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកដូចអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ ។ ដោយសារអនីតិសង្វាសមិនមានប្រព័ន្ធទ្រព្យសម្បត្តិរួម ដូច្នេះការបែងចែកទ្រព្យសម្បត្តិគឺខុសពីសហព័ទ្ធត្រង់ថា គ្មានបញ្ញត្តិច្បាប់កំណត់ពីការបែងចែកដូចសហព័ទ្ធ ប្រសិនបើ ការពិភាក្សាអំពីការព្រមព្រៀងបែងចែកទ្រព្យមិនសម្រេច។ តែមិនមែនមិនអាចធ្វើការបែងចែកបាននោះទេ ការបែងចែកទ្រព្យសម្បត្តិនៃអនីតិសង្វាស គឺយើងអាចធ្វើបានតាមរយៈ ការជម្រះបញ្ជី។ ការជម្រះបញ្ជីគឺអាស្រ័យទៅតាមរបបគតិយុត្តនៃទ្រព្យសម្បត្តិនីមួយៗដូចជា ទ្រព្យសម្បត្តិអនីតិសង្វាសជាកម្មសិទ្ធិអវិភាគ អនីតិសង្វាសបានបង្កើតក្រុមហ៊ុនណាមួយ និងសេចក្ដីចម្រើនដោយឥតហេតុជាដើម។ ដូច្នេះអនីតិសង្វាសអាចទាមទារបានដោយផ្អែកទៅតាមរបបគតិយុត្ត នៃទ្រព្យសម្បត្តិនីមួយៗដូចខាងក្រោម

**ក. កម្មសិទ្ធិអវិភាគ**

ដោយសារមិនមានប្រព័ន្ធ ទ្រព្យសម្បត្តិរួម ទើបបានជាគោលការណ៍អនីតិសង្វាសជនម្នាក់ៗទទួលទ្រព្យតែដើម្បីជាប្រយោជន៍ខ្លួន។ ភស្តុតាងដើម្បីបញ្ជាក់អំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួននោះអាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយ។ នៅពេលដែលទ្រព្យសម្បត្តិត្រូវបានបញ្ចូលគ្នា និង មិនអាចបែងចែកដាច់ពីគ្នាបាន ទ្រព្យសម្បត្តិទាំងនោះ នឹងត្រូវចាត់ទុកសម្បត្តិដែលក្រោមរបបគតិយុត្ត នៃកម្មសិទ្ធិអវិភាគ។[82]

[82] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា២០២ និង ២០៣

យើងអាចបកស្រាយទៅតាមប្រភេទនៃទ្រព្យសម្បត្តិនីមួយៗ ដែលទ្រព្យសម្បត្តិនោះត្រូវបែងចែកទៅតាមចំណែករបស់អនីតិសង្វាសជននីមួយៗ ប្រសិនបើមានភស្តុតាងអាចបញ្ជាក់ពីចំណែករបស់ខ្លួននោះបាន។ ប៉ុន្តែ ប្រសិនបើគ្មានភស្តុតាងបញ្ជាក់ពីចំណែករបស់ខ្លួនទេ នាំឲ្យទទួលបានចំណែកពាក់កណ្តាលស្មើគ្នា។ ម្យ៉ាងទៀតប្រសិនបើស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ[83] ហេតុនេះយើងអាចបែងចែកទ្រព្យតែមួយនោះ ទៅតាមចំណែកនៃកម្មសិទ្ធិអវិភាគម្នាក់ៗ ដោយត្រូវបានសន្មតថាទទួលបានចំណែកស្មើគ្នា។[84]

**ខ. កិច្ចសន្យាក្រុមហ៊ុន**

ក្នុងករណីមួយចំនួនអនីតិសង្វាសជនទាំងសងខាង អាចដាក់ហ៊ុនចូលគ្នា និងបង្កើតជាក្រុមហ៊ុនមួយ។ តែប្រសិនបើ មិនមានកិច្ចសន្យាក្រុមហ៊ុន[85] កើតឡើងនោះទេ នោះភាគីណាម្ខាងអាចលើកឡើងថា មិនមានការកកើតឡើងនូវក្រុមហ៊ុនដែលកើតឡើងតាមអង្គហេតុបាន។ ក្នុងទិដ្ឋភាពគតិយុត្តក្រុមហ៊ុនប្រភេទនេះត្រូវចាត់ទុកជាមោឃៈ។ ប៉ុន្តែ ការជម្រះបញ្ជីនៃក្រុមហ៊ុនប្រភេទនេះ ត្រូវឲ្យម្ចាស់ហ៊ុនម្នាក់ៗមានចំណែកភាគទុនស្មើៗគ្នា ហើយត្រូវបំពេញលក្ខខណ្ឌនៃកិច្ចសន្យាក្រុមហ៊ុនដូចជា៖ **ទី១** ការដាក់ភាគហ៊ុនចូលគ្នា **ទី២** ការចូលរួមក្នុងការចំណេញ **ទី៣** ការខាតបង់ **ទី៤** មានឆន្ទៈរួមគ្នាក្នុងការសហការគ្នា ។

ដោយយោងតាមការបកស្រាយខាងលើ វាដូចគ្នា នឹងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុនដែរ ដោយសំដៅទៅដល់កិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គលដើម្បីប្រកបកិច្ចការដោយសហការគ្នា ដោយភាគីនីមួយៗ ធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន[86] ហើយកិច្ចសន្យាក្នុងបញ្ញត្តិនេះ មិនចាំបាច់ធ្វើជាកិច្ចសន្យា ជាលាយល័ក្ខណ៍អក្សរនោះទេ។ហេតុដូច្នេះហើយបញ្ញត្តិនេះអាចយកទៅអនុវត្តនៅក្នុងករណីអនីតិសង្វាសបាន ដោយទាមទារឲ្យមានការចែកទ្រព្យសម្បត្តិតាមការជម្រះបញ្ជីបែបនេះ។ តែការជម្រះបញ្ជីក្រុមហ៊ុនប្រភេទនេះមិនមានបញ្ញត្តិណាមួយកំណត់ឲ្យបានច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែអាចយកជម្រះបញ្ជីបានទៅតាមកម្មសិទ្ធិអវិភាគ ដោយចាត់ទុកថា ទ្រព្យសម្បត្តិក្រុមហ៊ុន ស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគ។[87]

**គ. សេចក្តីចម្រើនឥតហេតុ**

---

[83] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ២០២

[84] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ២០៣

[85] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៦៩៩ ៧០០ និង ៧០១

[86] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ ,មាត្រា ៦៩៩

[87] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ , មាត្រា៧០១ កថាខណ្ឌទី១

លក្ខខណ្ឌ និងអានុភាពនៃសេចក្ដីចម្រើនដោយឥតហេតុ[88] មានន័យថា ទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឲ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ និង កើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ ដូច្នេះ បុគ្គលនោះត្រូវមានករណីកិច្ចសងប្រយោជន៍នោះត្រឹមកម្រិតដែលផលប្រយោជន៍នោះនៅមាន។ [89] ម្យ៉ាងទៀត នៅក្នុងករណីដែលបានទទួលការផ្ដល់តាវកាលិកពីអ្នកដទៃ ដោយយោងតាមកិច្ចសន្យានោះ ហើយប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាព ឬ ត្រូវបានបាត់បង់អានុភាព បុគ្គលដែលបានទទួលការផ្ដល់តាវកាលិកនោះត្រូវ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលខ្លួនបានទទួលដោយសារការផ្ដល់តាវកាលិកនោះឲ្យអ្នកដទៃដែលបានផ្ដល់តាវកាលិកនោះវិញ។[90] ដូចនេះ ករណីនេះអាចយកមកអនុវត្តបានចំពោះករណីអនីតិសង្វាស ។

**ឃ.ការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន**

នៅក្នុងនីតិបារាំងចាស់ ជាគោលការណ៍សន្តតិកម្មរវាងអនីតិសង្វាសជនមានសុពលភាព ។ ក៏ប៉ុន្តែ តុលាការត្រួតពិនិត្យមើលទៅលើមូលហេតុនៃសន្តតិកម្មនោះ ។ បើសិនជាវាផ្ទុយនឹងសីលធម៌ នោះត្រូវចាត់ទុកជាមោឃៈ ។ ឧទាហរណ៍ៈ ការផ្ដល់ប្រាក់រវាងអនីតិជនដើម្បីទំនាក់ទំនងផ្លូវភេទ ការផ្ដល់ឲ្យនេះត្រូវចាត់ទុកជាមោឃៈ ដោយសារមូលហេតុនៃអសីលធម៌ និងខុសច្បាប់ ។ តែក្រោយមកនៅឆ្នាំ ២០០៤ តុលាការ បានធ្វើការកែប្រែនូវយុត្តិសាស្ត្រ របស់ខ្លួនដោយចាត់ទុកថា មិនចាត់ទុកជាមោឃៈទេ សន្តតិកម្មរវាងអនីតិសង្វាសជនក្នុងអំឡុងពេលទំនាក់ទំនងផ្លូវភេទនោះ ដោយសារវាមិនផ្ទុយនឹងទំនៀមទំលាប់ដ៏ល្អទេ។[91]

**២.ករណីនៅជប៉ុន**

**២.១. អំណាចមេបាចំពោះកូន**

នៅប្រទេសជប៉ុន កូនដែលកើតឡើងក្នុងទំនាក់ទំនងអនីតិសង្វាស គឺមានតែអំណាចមេបាទោល ដែលជាម្ដាយប៉ុណ្ណោះ។ ហេតុដែលបណ្ដាលឲ្យមានតែម្ដាយពីព្រោះស្ត្រីជាអ្នកសម្រាលកូន គឺជាម្ដាយរបស់កូននោះ ចំពោះឪពុក គឺគ្មានមូលហេតុបិតុភាពតាមច្បាប់នោះទេ លើកលែងតែ

---

[88] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ ,មាត្រា ៧៣៦ និង មាត្រា៧៣៧

[89] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ ,មាត្រា ៧៣៦ កថាខណ្ឌទី១

[90] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ , មាត្រា ៧៣៦ កថាខណ្ឌទី២

[91] ក្រមរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/១២៧០/០៣០,០៨ធ្នូ ២០០៧ មាត្រា ៣៥៤

ឪពុកបានទទួលស្គាល់ចំពោះកូនដោយស្ម័គ្រចិត្ត និងបានចុះសំបុត្រកំណើតកូនដោយដាក់ឈ្មោះខ្លួនថាជាឪពុករបស់កូននោះ វាជាហេតុនាំឲ្យមានទំនាក់ទំនងជាឪពុក និងកូនកើតឡើង។[92]

អនីតិសង្វាសជាស្ត្រី ដែលជាម្តាយមិនអាចទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនពីឪពុកបាននោះទេ លើកលែងតែឪពុកនោះបានទទួលស្គាល់កូន។ ប្រសិនបើឪពុកទទួលស្គាល់កូនអាចពិភាក្សា និងកំណត់ជាមួយម្តាយអំពីរបៀបចូលប្រាស្រ័យទាក់ទងគ្នា និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន។[93]

**២.២.សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន**

នៅប្រទេសជប៉ុន ចំពោះទំនាក់ទំនងអនីតិសង្វាស ក្នុងករណីដែលមានការទទួលស្គាល់ទំនាក់ទំនងឪពុក និងកូនបានកើតឡើងនោះឪពុក ឬម្តាយណាដែលមិនមានអំណាចមេបាចំពោះកូនអាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបានដូចក្នុងករណីអាពាហ៍ពិពាហ៍ដែរ ព្រមទាំងមានកាតព្វកិច្ចទទួលខុសត្រូវលើបន្ទុកសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន។ ការកំណត់អំពីការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រងចិញ្ចឹមថែរក្សាកូនធ្វើឡើងដោយឆន្ទៈសេរីរបស់ភាគី លើកលែងតែមានការពិភាក្សាគ្នាមិនត្រូវគ្នា ។

ការលើកឡើងខាងលើបែបនេះគឺស្របទៅ នឹងកថាខ័ណ្ឌទី៣ មាត្រា៨២១ នៃក្រមរដ្ឋប្បវេណីជប៉ុនបានចែងថា ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និងកំណត់ជាមួយម្តាយ អំពីរបៀបជួបប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងរក្សាកូនបាន។ ប្រសិនបើស្ថិតក្នុងករណីពុំបានសម្រេច ឬ ប្រសិនបើពុំអាចធ្វើការពិភាក្សាគ្នាបានទេ ត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ហើយវាគឺជាការចាំបាច់បំផុតក្នុងការកំណត់និងផ្លាស់ប្តូរដែលត្រូវទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយតុលាការយកប្រយោជន៍របស់កូនជាអាទិភាព និងដោយពិចារណាទៅលើស្ថានភាពសេដ្ឋកិច្ចរបស់ឪពុក ឬម្តាយនោះ ។

**២.៣.ការទាមទារផ្នែកទ្រព្យសម្បត្តិ**

អនីតិសង្វាសពុំមានប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធរួម និងប្រព័ន្ធទ្រព្យសម្បត្តិដោយឡែកដូចអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ដូច្នេះអនីតិសង្វាសអាចទាមទារទ្រព្យសម្បត្តិបានដោយផ្អែកទៅតាមរបបគតិយុត្ត នៃទ្រព្យសម្បត្តិនីមួយៗដូចខាងក្រោម៖

**ក. កម្មសិទ្ធិអវិភាគ**

[92] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៧៧៩ ដល់ ៧៨៥

[93]ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៨២១

ដោយសារមិនមានប្រព័ន្ធ ទ្រព្យសម្បត្តិរួម ទើបបានជាគោលការណ៍អនីតិសង្វាសជនម្នាក់ៗទទួលទ្រព្យតែជាប្រយោជន៍ខ្លួន។ ភស្តុតាងដើម្បីបញ្ជាក់អំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួននោះអាចត្រូវបានបង្ហាញតាមគ្រប់មធ្យោបាយ។ នៅពេលដែលទ្រព្យសម្បត្តិត្រូវបានបញ្ចូលគ្នា និង មិនអាចបែងចែកដាច់ពីគ្នាបាន ទ្រព្យសម្បត្តិទាំងនោះ នឹងត្រូវចាត់ទុកសម្បត្តិដែលក្រោមរបបគតិយុត្ត នៃកម្មសិទ្ធិអវិភាគ។[94]

យើងអាចបកស្រាយទៅតាមប្រភេទនៃទ្រព្យសម្បត្តិនីមួយៗ ដែលទ្រព្យសម្បត្តិនោះត្រូវបែងចែកទៅតាមចំណែករបស់អនីតិសង្វាសជននីមួយៗ ប្រសិនបើមានភស្តុតាងអាចបញ្ជាក់ពីចំណែករបស់ខ្លួនបាន។ ប៉ុន្តែ ប្រសិនបើគ្មានភស្តុតាងបញ្ជាក់ពីចំណែករបស់ខ្លួនទេ នាំឲ្យទទួលបានចំណែកពាក់កណ្តាលស្មើគ្នា។ ម្យ៉ាងទៀតប្រសិនបើស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួនដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ[95] ហេតុនេះយើងអាចបែងចែកទ្រព្យតែមួយនោះ ទៅតាមចំណែកនៃកម្មសិទ្ធិអវិភាគម្នាក់ៗ ដោយត្រូវបានសន្មត់ថាទទួលបានចំណែកស្មើគ្នា។[96]

**ខ. កិច្ចសន្យាក្រុមហ៊ុន**

ក្នុងករណីមួយចំនួនអនីតិសង្វាសជនទាំងសងខាង អាចដាក់ហ៊ុនចូលគ្នាបាន និងបង្កើតជាក្រុមហ៊ុនមួយ។ តែប្រសិនបើ មិនមានកិច្ចសន្យាក្រុមហ៊ុន[97] កើតឡើងនោះទេ នោះភាគីណាម្ខាងនៃអនីតិសង្វាសអាចលើកឡើងថា មានការកកើតឡើងនូវក្រុមហ៊ុនដែលកើតឡើងតាមអង្គហេតុបាន។ ក្នុងទិដ្ឋភាពគតិយុត្តក្រុមហ៊ុនប្រភេទនេះត្រូវចាត់ទុកជាមោឃៈ។

ដោយយោងតាមការបកស្រាយខាងលើ វាដូចគ្នា និងលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាក្រុមហ៊ុន ដោយសំដៅទៅដល់កិច្ចសន្យាបង្កើតជាក្រុម ដែលគ្មានការរៀបចំលក្ខណៈជានីតិបុគ្គលដើម្បីប្រកបកិច្ចការដោយសហការគ្នា ដោយភាគីនីមួយៗ ធ្វើការវិនិយោគទ្រព្យធនរៀងៗខ្លួន[98] ហើយកិច្ចសន្យាក្នុងបញ្ញត្តិនេះ មិនចាំបាច់ធ្វើជាកិច្ចសន្យា ជាលាយល័ក្ខណ៍អក្សរនោះទេ។ ហេតុដូច្នេះហើយ បញ្ញត្តិនេះអាចយកអនុវត្តនៅក្នុងករណីអនីតិសង្វាសបាន ដោយទាមទារឲ្យមានការចែកទ្រព្យសម្បត្តិតាមការជម្រះបញ្ជីបែបនេះ។ តែការជម្រះបញ្ជីក្រុមហ៊ុនប្រភេទនេះមិនមានបញ្ញត្តិណា

[94] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា១៤៩ និង ១៥០
[95] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ១៤៩
[96] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ១៥០
[97] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៦៦៧
[98] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៦៦៧

កំណត់ឲ្យបានច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែអាចយកជម្រះបញ្ជីបាន ទៅតាមកម្មសិទ្ធិអវិភាគ ដោយចាត់ទុកថា ទ្រព្យសម្បត្តិក្រុមហ៊ុន ស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគ។[99]

**គ. សេចក្តីចម្រើនឥតហេតុ**

ករណីនេះ នៅប្រទេសជប៉ុន លក្ខខណ្ឌ និងអានុភាពនៃសេចក្តីចម្រើនដោយឥតហេតុ[100] មានន័យថាទោះបីជាគ្មានមូលហេតុលើផ្លូវច្បាប់ក៏ដោយ ចំពោះបុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ហើយធ្វើឲ្យកើតមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលនោះ ដូច្នេះបុគ្គលនោះត្រូវមានករណីកិច្ចសងប្រយោជន៍នោះ ត្រឹមកម្រិតដែលផលប្រយោជន៍នោះនៅមាន។[101] ម្យ៉ាងទៀត នៅក្នុងករណីដែលបានទទួលការផ្តល់តាវកាលិកពីអ្នកដទៃ ដោយយោងតាមកិច្ចសន្យានោះ ហើយប្រសិនបើកិច្ចសន្យានោះពុំមានអានុភាព ឬ ត្រូវបានបាត់បង់អានុភាព ឬ ត្រូវបានបាត់បង់អានុភាពបុគ្គល ដែលបានទទួលការផ្តល់តាវកាលិកនោះត្រូវ មានករណីយកិច្ចត្រូវសងផលប្រយោជន៍ដែលខ្លួន បានទទួលដោយសារការផ្តល់តាវកាលិកនោះ ឲ្យអ្នកដទៃដែលបានផ្តល់តាវកាលិកនោះវិញ។[102] ដូចនេះ ករណីនេះអាចយកមកអនុវត្តបានចំពោះករណីអនីតិសង្វាស ។

**ឃ.ការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន**

នៅប្រទេសជប៉ុន ការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន គឺគ្មានចែងនៅក្នុងច្បាប់ណាឡើយ។ ជាក់ស្តែង ការផ្ទេរទ្រព្យសម្បត្តិរវាងអនីតិសង្វាសជន គឺអាស្រ័យទៅតាមការសម្រេចរបស់តុលាការជប៉ុន។

---

[99] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា៦៦៨ កថាខណ្ឌទី១

[100] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៧០៣ និង មាត្រា៧០៤

[101] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៧០៣ កថាខណ្ឌទី១

[102] ក្រមរដ្ឋប្បវេណីជប៉ុនឆ្នាំ១៩៨០ មាត្រា ៧០៣ កថាខណ្ឌទី២

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមការសិក្សាស្រាវជ្រាវប្រធានបទ **ប្រៀបធៀបអំពីអនីតិសង្វាសកម្ពុជា-ជប៉ុន** យើងអាចនិយាយបានថា ករណីអនីតិសង្វាសកម្ពុជា និង ករណីអនីតិសង្វាសជប៉ុន មានលក្ខណៈដូចគ្នា និងខុសគ្នាមួយចំនួន ។

ចំពោះភាពដូចគ្នា គឺទាំងប្រទេសកម្ពុជា និងប្រទេសជប៉ុន អនីតិសង្វាស ជាចំណងក្រៅគតិយុត្តដែលបុរសនិងស្ត្រីរស់នៅជាមួយគ្នា ដូចជាបុរសនិងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ដែរ។ ម៉្យាងវិញទៀត អនីតិសង្វាស គឺជាសមគ្គសង្វាសតាមព្រឹត្តន័យមួយ ដែលមានភាពខុសគ្នាពីអាពាហ៍ពិពាហ៍ ដូច្នេះវាបង្កើតអានុភាពគតិយុត្តដោយឡែក ខុសពីអាពាហ៍ពិពាហ៍ស្របច្បាប់។ បន្ថែមពីនេះទៅទៀត ទាំងប្រទេសកម្ពុជា និងប្រទេសជប៉ុន ថ្វីត្បិត ច្បាប់មិនបានកំណត់ពីការការពារផលប្រយោជន៍ ក្នុងការគ្រប់គ្រងប្រើប្រាស់ទ្រព្យសម្បត្តិរបស់អនីតិសង្វាសនៅអំឡុងពេលមានទំនាក់ទំនង និងក្រោយការរំលាយទំនាក់ទំនងក៏ដោយ ក៏មានលក្ខណៈពិសេសមួយចំនួនដែលបានធានានូវស្ថេរភាពនៃទ្រព្យសម្បត្តិដែលរកបានរៀងៗខ្លួន។ ក្រៅពីនេះ ទោះបីជាអនីតិសង្វាសគ្មានប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ និងប្រព័ន្ធទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាដូចសហព័ទ្ធក៏ដោយ ក៏អនីតិសង្វាសជន អាចធ្វើកិច្ចសន្យាកំណត់អំពីទ្រព្យសម្បត្តិដែលមានលក្ខណៈជាកិច្ចសន្យាឯកជនបាន។ ហើយក៏មានបទបញ្ញត្តិមួយចំនួនអាចយកមកបកស្រាយអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៃអនីតិសង្វាសបានដែរ ប្រសិនបើ សកម្មភាពអនីតិសង្វាសកើតឡើងតាមការកំណត់ ឬ ស្របតាមលក្ខខណ្ឌនៃបញ្ញត្តិ ដែលយើងបានបកស្រាយរួចមកហើយក្នុងសារណានេះ មានដូចជា កម្មសិទ្ធិអវិភាគ កិច្ចសន្យាក្រុមហ៊ុនជាដើម។ ចំពោះបណ្តឹងវិញ ភាគច្រើនបណ្តឹងនៅប្រទេសកម្ពុជា និងជប៉ុន គឺដើមចោទប្តឹងទាមទារ ឈប់រស់នៅជាអនីតិសង្វាស សុំសិទ្ធិអំណាចមេបាលើកូន និងសុំទាមទារគ្រប់គ្រង កាន់កាប់ទ្រព្យសម្បត្តិ។ ប្រសិនបើភាគីនៃអនីតិសង្វាសមានឆន្ទៈរំលាយអនីតិសង្វាស ភាគីនោះអាចធ្វើឡើងតាមការព្រមព្រៀងគ្នាបាន ដោយហេតុថា អនីតិសង្វាសគឺកើតឡើងតាមព្រឹត្តន័យ ឬដោយសេរីហើយលក្ខណៈជាក់ស្តែងមិនមែនជាចំណងគតិយុត្ត ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់វិជ្ជមាននានានៅកម្ពុជា និងជប៉ុនឡើយ ប៉ុន្តែអនីតិសង្វាសជន ក៏អាចទាមទារផ្តាច់សមគ្គសង្វាសបានស្របទៅការសម្រេចតាមផ្លូវតុលាការបានផងដែរ។ករណីដែលអនីតិសង្វាសជនមានបញ្ហាក្នុងការរស់នៅជាមួយគ្នា ក៏ដូចជាមានភាពចម្រុងចម្រាស់គ្នា ម្យ៉ាងទៀតពួកគាត់អាចសុំសិទ្ធិទាមទារកាន់កាប់នូវទ្រព្យសម្បត្តិឬអំណាចមេបាលើកូនបាន។ពេលដែលមាន

កាស្នើសុំបែបនេះ នោះតុលាការសម្រេចសេចក្ដីដោយផ្អែកលើភស្តុតាង និង ផ្អែកលើការយល់ឃើញ ឬ ឆន្ទានុសិទ្ធិក្រៅវង្វង់ច្បាប់ ។

ដោយឡែកបើយើងពិនិត្យមើលភាពខុសគ្នារបស់អនីតិសង្វាសកម្ពុជាវិញឃើញថាមានចំណុចមួយចំនួនដូចជា៖**ករណីកម្ពុជា:** ទាក់ទងនឹងមូលហេតុនៃការបង្កើតចំណងអនីតិសង្វាសនៅកម្ពុជា គឺបុរស និងស្ត្រីទាំងឡាយណា ដែលបានរស់នៅជាមួយគ្នារយៈពេលយូរ ដោយមិនគោរពតាមបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍នៃក្រមរដ្ឋប្បវេណី នោះទំនាក់ទំនងរបស់បុរសស្ត្រីនោះនឹងក្លាយទៅជាអនីតិសង្វាសជាស្វ័យប្រវត្តិ។ ចំពោះការរស់នៅជាមួយគ្នា និងការយកគ្នាជាប្ដីនិងប្រពន្ធរវាងមនុស្សដែលមានភេទដូចគ្នា នៅប្រទេសកម្ពុជាដោយសារការទទួលស្គាល់នូវសិទ្ធិសេរីភាពរបស់បុគ្គលម្នាក់ៗដែលមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣។ ហេតុដូចនេះភេទដូចគ្នា កំពុងត្រូវបានអ្នកច្បាប់ធ្វើការពិចារណាថាតើជាអនីតិសង្វាស ឬស្ថិតក្នុងស្ថានភាពផ្សេងទៀត។

**ករណីជប៉ុន:** ទាក់ទងនឹងការបង្កើតចំណងអនីតិសង្វាសនៅប្រទេសជប៉ុនវិញ មិនមែនមានតែការមិនគោរពតាមបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍ នៃក្រមរដ្ឋប្បវេណីប៉ុណ្ណោះទេ គឺអនីតិសង្វាសមិនអាចរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់បាន ដោយសារស្ថានភាពផ្លូវចិត្ត ឬមានអាយុច្រើនពេក (អាយុ ៧០ឡើងទៅ) មិនចង់មានចំណងផ្លូវច្បាប់ ឬមិនចង់ដូរត្រកូលជាអាទិ៍ ភាគីនៃអនីតិសង្វាសយឺតយ៉ាវក្នុងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ភាគីនៃអនីតិសង្វាសយល់ថាការរៀបអាពាហ៍តាមប្រពៃណីមានសារៈសំខាន់ជាងការរៀបអាពាហ៍ពិពាហ៍តាមច្បាប់ជាអាទិ៍ ក៏ជាមូហេតុនៃការបង្កើតចំណងអនីតិសង្វាសផងដែរ។ ទាក់ទងអនីតិសង្វាស មានភេទដូចគ្នា នៅប្រទេសជប៉ុន មិនត្រូវទទួលស្គាល់នោះទេ ដោយហេតុថាផ្ទុយសណ្ដាប់ធ្នាប់សាធារណៈ, ទំនៀមទំលាប់ល្អរបស់សង្គម និងប្រពៃណីរបស់សង្គមជាតិជប៉ុន ។

សរុបសេចក្ដីមក យើងយល់ឃើញថា ថ្វីត្បិតអនីតិសង្វាស មិនមានការកំណត់អំពីទំនាក់ទំនងទ្រព្យសម្បត្តិឲ្យបានច្បាស់លាស់យ៉ាងណាក៏ដោយ ក៏ការជ្រើសរើសការរស់នៅជាអនីតិសង្វាសនៅតែមានការកើនឡើង ជាពិសេសនៅប្រទេសជឿនលឿន។ ដូច្នេះហើយ សព្វថ្ងៃនេះរឿងក្ដីទាក់ទងអនីតិសង្វាសគឺកំពុងមានភាពច្របូកច្របល់យ៉ាងខ្លាំង ទាំងនៅក្នុងប្រទេសកម្ពុជា និងជប៉ុន ដែលទាមទារឲ្យមានការកំណត់ច្បាប់ថ្មីមួយឲ្យមានភាពច្បាស់លាស់ ដើម្បីគ្រប់គ្រងទៅលើអនីតិសង្វាសនេះ។ ម្យ៉ាងទៀត អាពាហ៍ពិពាហ៍ស្របច្បាប់ និងអនីតិសង្វាសត្រូវតែកំណត់ពីភាពដាច់ដោយឡែកគ្នា ពីព្រោះបើមិនដូច្នេះទេ វានឹងបង្កផលគ្រោះថ្នាក់ដល់អ្នករស់នៅជាអនីតិសង្វាសបែបនេះ។

# អនុសាសន៍

# អនុសាសន៍

ដោយសារតែប្រទេសកម្ពុជា និងជប៉ុន ទាក់ទងនឹងបញ្ហាអនីតិសង្វាសពុំមានច្បាប់ណាមួយកំណត់ជាក់លាក់នៅឡើយទេ។ ដូច្នេះ ការយកបទបញ្ញត្តិ ស្តីពីអាពាហ៍ពិពាហ៍នៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ និងក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០ មកអនុវត្តក្នុងរឿងក្តីអនីតិសង្វាស គឺវាកំពុងតែធ្វើឲ្យមានភាពច្របូកច្របល់ក្នុងប្រព័ន្ធច្បាប់កម្ពុជា និងជប៉ុន ។

បន្ថែមពីនេះទៅទៀត អនីតិសង្វាសពុំមានច្បាប់ណាមួយកំណត់ជាក់លាក់នៅឡើយ ពោលគឺយើងសង្កេតឃើញថា នៅតាមសាលាជំនុំជម្រះក្តីទាំងកម្ពុជា និងជប៉ុន គឺតុលាការធ្វើការវិនិច្ឆ័យដោយមានការបកស្រាយច្បាប់ផ្សេងៗគ្នាទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយពុំមានភាពឯកឆន្ទរួមមួយនៅឡើយ។ ដូចនេះ នៅពេលដែលមានវិវាទកើតឡើងទាក់ទងទៅនឹងអនីតិសង្វាស តុលាការកម្ពុជា ក៏ដូចជាតុលាការជប៉ុនមួយចំនួនបានបំភ្លេចចោលនូវការសំអាងដែលកើតចេញពីច្បាប់ហើយជំនួសមកវិញនូវសំអាងដែលស្របទៅតាមឆន្ទៈរបស់ខ្លួន។ ហេតុផលទាំងនេះហើយដែលធ្វើឲ្យរឿងក្តីអនីតិសង្វាសមានភាពច្របូកច្របល់គ្នាយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា និងជប៉ុន។ ផ្ទុយទៅវិញ ករណីដែលតុលាការធ្វើការវិនិច្ឆ័យដោយមានការបកស្រាយច្បាប់ ចំពោះរឿងក្តីអនីតិសង្វាសបាន លុះត្រាតែរឿងក្តីនៃអនីតិសង្វាសនោះ វាមានភាពស្រដៀងគ្នាទៅនឹងដែនកំណត់នៃបទបញ្ញត្តិស្តីពីអាពាហ៍ពិពាហ៍នៃក្រមរដ្ឋប្បវេណីរបស់កម្ពុជា និងជប៉ុនតែប៉ុណ្ណោះ។

មួយវិញទៀត បើយើងសង្កេតទៅមើលមូលហេតុដែលនាំឲ្យមានអនីតិសង្វាសកើតឡើងគឺ ដោយសារតែប្រជាជនមួយចំនួនគិតថានីតិវិធីនៃការសុំចុះបញ្ជីអាពាហ៍ពិពាហ៍មានភាពសាំញ៉ាំច្រើន ហើយពួកគាត់គិតថាការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីគឺគ្រប់គ្រាន់ហើយ។

ជាដំណោះស្រាយនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា និងជប៉ុន ក្នុងនាមយើងជាពលរដ្ឋក៏ដូចជានិស្សិតច្បាប់ សូមសំណូមពរដល់អាជ្ញាធរមូលដ្ឋានជួយសម្រួលនីតិវិធីនៃការចុះបញ្ជីអាពាហ៍ពិពាហ៍ឲ្យមានភាពងាយស្រួលជាងមុនដើម្បីឲ្យប្តីប្រពន្ធដែលរៀបការតាមប្រពៃណីអាចទៅចុះបញ្ជីអាពាហ៍ពិពាហ៍បានគ្រប់គ្នា។

ម្យ៉ាងវិញទៀតក៏សូមធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវគោរពឲ្យបាននូវគោលការណ៍ និងលក្ខខណ្ឌផ្សេងៗក្នុងច្បាប់ ជាពិសេសលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ព្រោះ ការមិនគោរពនូវលក្ខខណ្ឌទាំងនោះនឹងបង្កឲ្យមានភាពស្មុគស្មាញ និងផលលំបាកជាច្រើនក្នុងទំនាក់ទំនងជាប្តីប្រពន្ធ។

លើសពីនេះទៀតយើងខ្ញុំក៏សូមសំណូមពរដល់អំណាចនីតិបញ្ញត្តិនៃប្រទេសទាំងពីរ មានការបង្កើតច្បាប់ ឬ បទដ្ឋានគតិយុត្តណាមួយទាក់ទងទៅនឹងអនីតិសង្ហាសជាចាំបាច់ ដើម្បីឲ្យមានការអនុវត្តឯកភាពគ្នាមួយនៅទូទាំងប្រទេស និងចៀសវាងវិវាទច្បាប់ធ្ងន់ធ្ងរនាពេលអនាគត ជាពិសេស គឺវិវាទរវាងច្បាប់ និងប្រពៃណីរបស់សង្គម។ ដើម្បីឲ្យច្បាប់ទាក់ទងទៅនឹងអនីតិសង្ហាសមានប្រសិទ្ធិភាពក្នុងការអនុវត្ត យើងគួរតែបង្កើតច្បាប់នេះឲ្យសមស្របទៅនឹងសង្គមកម្ពុជា និងជប៉ុន ព្រោះថាគោលបំណងនៃការបង្កើតច្បាប់ គឺដើម្បីឲ្យមនុស្សធ្វើអំពើល្អ និងទាត់ចោលនូវអំពើអាក្រក់ ហើយផ្លាស់ប្តូរឥរិយាបទ ដោយទទួលខុសត្រូវនូវកំហុស ក្នុងនាមជាប្រជាពលរដ្ឋ។ ចំណែកឯអំណាចនីតិប្រតិបត្តិ គឺមានតួនាទីជានាការអនុវត្ត ជាអ្នកពង្រឹងការអនុវត្តច្បាប់តាមនីតិវិធីច្បាប់ដែលប្រគល់ឲ្យ និង អនុវត្តឲ្យមានប្រសិទ្ធិភាពខ្ពស់ទូទាំងប្រទេស។ ចំណែកអំណាចតុលាការវិញមានតួនាទីដាក់ទណ្ឌកម្ម ទៅលើអនីតិសង្ហាជនដែលបានប្រព្រឹត្តខុស តាមរយៈការជំនុំជំរះក្តី៕

# ឯកសារយោង

# ឯកសារយោង

## ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា,លេខ នស/រកម/០៧០៦/០២១ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណីកម្ពុជា, លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌកម្ពុជា,លេខ នស/រកម/១១០៩/០២២,២០១០
- ក្រមរដ្ឋប្បវេណីជប៉ុន ឆ្នាំ១៩៨០
- ក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុន ឆ្នាំ១០៩៦
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ, លេខ ៥៦ក្រ, ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៨៩


## សៀវភៅនិងអត្ថបទផ្សេងៗ


- ចក សម្បត្តិ បោះពុម្ពឆ្នាំ២០១៤ អនីតិសង្វាស
- ណូម៉ូរ៉ា តូយ៉ូហ៊ីរ៉ូ, សេចក្តីផ្តើមនីតិរដ្ឋប្បវេណី ឆ្នាំ២០១១
- អ៊ីវ ប៉ូលី និង ចៅប៊ុនហួន (អត្ថបទធ្វើបទបង្ហាញ)
- អ៊ីឈីដា គីឆុ, នីតិរដ្ឋប្បវេណីភាគទី៤ ស្តីពីញាតិនិងសន្តតិកម្ម បោះពុម្ពលើកទី៦ ឆ្នាំ២០០៤
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគទី៥ ឆ្នាំ២០១០